# ខ្មែរប៉ុស្តិ៍ ស.រ.អា

# KhmerPost USA

Printing The Cambodian World News

VOL. 06 ISSUE 92 Oct 07th - 20th, 2011

សុបិន : (267) 253-3947, សែម : (781) 244-0522

MASSACHUSETTS
217 APPLETON ST.
LOWELL, MA 01852
PENNSYLVANIA
438 LINDLEY AVE.
PHILADELPHIA, PA 19120
RHODE ISLAND
NEW JERSEY


មាតិការរឿង ទំព័រ


១-កម្មវិធីប្រមូលថវិការជួយជនក្រីក្រ................................០៣
២-សម្បត្តិមនុស្សចាស់ ................................០៧
៣-ប្រវត្តិវណសិប្បជាតិរំដោះប្រជាពលរដ្ឋខ្មែរ................................១០
៤- ប្រវត្តិសាស្ត្រកម្ពុជា................................១៨
៥- The Cambodia Daily................................០៨ & ១៥


# បទសម្ភាសន៍ជាមួយអគ្គលេខាធិការ គណបក្សសិទ្ធិមនុស្ស

**ដោយ : ពិន សំខុន**



*លោក យ៉ែម ប៊ុញ្ញារិទ្ធ ជាតំណាងរាស្ត្រមណ្ឌល ព្រៃវែង នឹងជាអគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស បានមកធ្វើទស្សនកិច្ច២ថ្ងៃនៅក្រុងហ្វីឡាដែលហ្វៀ រដ្ឋផែនស៊ីវេនា កាលពីថ្ងៃអាទិត្យនិងថ្ងៃច័ន្ទទី២និងទី៣ ខែតុលាឆ្នាំ២០១១បានផ្តល់បទសម្ភាសន៍ជាមួយខ្មែរប៉ុស្តិ៍សហរដ្ឋអាមេរិក ដែលមានអត្ថន័យដូចតទៅ :*

**ខ្មែរប៉ុស្តិ៍ :** តើបេសកកម្មលោកមកហ្វីឡាដែលហ្វៀ ដើម្បីធ្វើអ្វី ?

**យ៉ែម ប៊ុញ្ញារិទ្ធ :** ខ្ញុំចេញមកពីកម្ពុជាទៅប្រទេសបារាំងរួចមកសហរដ្ឋអាមេរិក ដើម្បីជួបជុំថ្នាក់ដឹកនាំគណបក្សមួយចំនួនខាងមូស្ទុន រដ្ឋម៉ាសាឈូសែត ខាងឡូវែល ហើយថ្ងៃនេះមកហ្វីឡា ដែលហ្វៀ ។

**ខ្មែរប៉ុស្តិ៍ :** តើសាខាបក្សរបស់លោកកំពុងតែមានបញ្ហាអ្វី ឬក៏មកផ្តល់ព័ត៌មានពីស្ថានភាពនយោបាយទូទៅនៅកម្ពុជា ?

**យ៉ែម ប៊ុញ្ញារិទ្ធ :** គឺជា **តទៅទំព័រទី ៤**

# ភាពយន្តឯកសារ "នរណាសម្លាប់ ជា វិជ្ជា" ត្រូវបាន ដាក់បញ្ចាំងនៅជាសាធារណៈ នៅហ្វីឡាដែលហ្វៀ

**ដោយ : អ៊ុម លឿម**

ភាពយន្តឯកសារមួយ ដែលមានចំណងជើងថា "នរណាសម្លាប់ ជា វិជ្ជា" ដែលត្រូវបានគេចំណាយពេលយ៉ាងយូរហូតដល់៨ឆ្នាំទើបផលិតរួចរាល់នោះ ឥឡូវត្រូវបានគេចាក់បញ្ចាំងជាសាធារណៈនៅក្នុងបរិវេណវត្ត "ព្រះពុទ្ធរង្សី" ស្ថិតនៅទីក្រុងហ្វីឡាដែលហ្វៀខាងត្បូងកាលពីថ្ងៃច័ន្ទ ទី២៥ ខែកញ្ញា កន្លងមកនេះ ទោះបីជាខ្សែភាពយន្តនេះ ជាឆ្អឹងទទឹងករបស់រដ្ឋាភិបាលកម្ពុជា ហើយក៏ត្រូវអាជ្ញាធរក្រុងភ្នំពេញ បដិសេធមិនឱ្យចាក់បញ្ចាំង នឹងមានការរារាំងជាច្រើន លើកច្រើនគ្រាយ៉ាងណាក៏ដោយចុះ ។

ទីបំផុតអាចិកំបាំងមួយចំនួនក៏ត្រូវ

**តទៅទំព័រទី ១៧**




# ក្រសួងសេវាសុខភាពចរិយានឹងពិការភាពបញ្ញា ប្រចាំហ្វីឡាដែលហ្វៀ ប្រតិកម្មចំពោះសោកនាដកម្ម ពីខែកញ្ញានៅហ្វីឡាដែលហ្វៀ

**ដោយបកប្រែ : អាថើរ ស៊ីអ៊ីវិន ជីអរ**

ក្រសួងសេវាសុខភាពចរិយានឹងពិការភាពបញ្ញា "DBHIDS" ប្រចាំក្រុងហ្វីឡាដែលហ្វៀ សូមសំដែងនូវការចូលរួមមរណទុក្ខ ដ៏ជ្រាលជ្រៅចំពោះក្រុមគ្រួសារ ញាតិមិត្ត នឹងទូទាំងសហគមន៍ ដែលទទួលរងនូវព្រឹត្តិការណ៍ ដ៏កម្រនឹងដ៏តក់ស្លុត ដែលកើតឡើងនាដើមខែកញ្ញា នៅហ្វីឡាដែលហ្វៀ នេះ ។

កាលណាមានសោកនាដកម្មកើតក្នុងសហគមន៍ដូចមួយនោះ យើងតែងតែស្វែងរកចម្លើយមួយនៅលើសំណួរជាច្រើន គេតែងឆ្លើយដោយស្មានថាបុគ្គលដែលមានបញ្ហាខួរក្បាលតែងបង្ហាញរោគសញ្ញាថា ធ្វើអំពើហិង្សា ។ ការវាយស្មានរបៀបនេះ រឹតតែធ្វើឱ្យមានស្លាកស្នាមមិនគប្បីថែមទៀត ការពិតវាអាចកើតអំពើហិង្សាដូច្នោះដែរ តែភាពគ្រោះថ្នាក់វាកើនឡើង ភ្ជាប់ជាមួយនឹងការប្រើគ្រឿងស្រវឹង ។ ការស្រាវជ្រាវបានបង្ហាញថា អ្នកមានជម្ងឺចរិយាមានប្រព្រឹត្តហិង្សាតិចតួចប៉ុណ្ណោះ ក្នុងចំណោមអំពើហិង្សាទាំងអស់ដែលកើតឡើងជាទូទៅអ្នកមានវិបត្តិចរិយា គឺជាមនុស្ស "អហិង្សា" ។ ជាការពិតណាស់ ដែលការសិក្សាទាំងឡាយបានរកឃើញថា មនុស្សដែលមានវិបត្តិផ្លូវចិត្តច្រើនតែរងគ្រោះដោយសារអំពើហិង្សា **តទៅទំព័រទី 5**

## The City of Philadelphia Department of Behavioral Health and Intellectual disAbility Services' Reaction to the September Tragedy in Philadelphia

~by Arthur C. Evans Jr., Ph.D



The Philadelphia Department of Behavioral Health and Intellectual disAbility Services (DBHIDS) offers its deepest sympathy for the family, friends, and the broader community impacted by the rare and traumatic event that occurred in Philadelphia in early September.

When a tragedy occurs in a community such as this one, we all seek an explanation. While there are many questions, people often assume that the individual has a mental health diagnosis which caused him or her to be violent. This assumption can contribute to people with mental or behavioral health challenges or substance-related conditions being further stigmatized. It also makes it less likely that individuals in need of help will receive appropriate care. Some people with mental health challenges do become violent, and the risk of this is **Continued to page 4**


GENERAL DENTISTRY

# ហួ ឌួង ពេទ្យធ្មេញសម្រាប់គ្រួសារ

466 Merrimack Street. Lowell, MA 01854
( Near City Hall ) / 978-441-1005

HOA DUONG, D.M.D., P.C.
GENERAL DENTISTRY

គ្រូពេទ្យជំនាញនិងមានបទពិសោធន៍
ច្រើនឆ្នាំក្នុងការពិនិត្យ
ថែរក្សា និងព្យាបាលជម្ងឺធ្មេញទូទៅ



Open: Monday, Tuesday, Wednesday, and Friday
from 10 a.m. – 6 p.m.
Saturday: from 10 a.m. – 4 p.m.
Closed: Thursday & Sunday
We accept all dental insurance & Medicaid



យើងទទួលយកគ្រប់ក្រុមហ៊ុនធានារ៉ាប់រង
សុខភាព និងការធានារ៉ាប់រងសុខភាពមនុស្សចាស់
យើងបើកទ្វារទទួលភ្ញៀវ ៥ថ្ងៃ ក្នុងមួយសប្តាហ៍
បិទទ្វារ : ថ្ងៃព្រហស្បត្តិ៍ និងថ្ងៃ អាទិត្យ
ទូរស័ព្ទដើម្បីណាត់ជួប (978) 441-1005
ម៉ោងធ្វើការពីម៉ោង 10ព្រឹក ដល់ 6ល្ងាច
ថ្ងៃសៅរ៍ ពីម៉ោង 10ព្រឹក ដល់ 4រសៀល
យើងមានបុគ្គលិកនិយាយភាសាខ្មែរ

978-441-1005

# យើងនៅរង់ចាំជួយដល់លោកអ្នក !

●● ប្រសិនបើលោកអ្នក :

- មានអារម្មណ៍អស់សង្ឃឹម ឬរំភើបខ្លាំង
- មានភាពធាប់ទឹង
- ចង់នៅតែឯកឯង
- មានទឹកចិត្តផ្លាស់ប្ដូរ
- មានភាពច្របូកច្របល់ក្នុងខ្លួន
- មានអារម្មណ៍ធុញថប់
- មានអារម្មណ៍រំជួលចិត្ត ឬព្រួយបារម្ភ
- ផ្លាស់ប្ដូរទម្លាប់ដំណេក
- ផ្លាស់ប្ដូរទម្លាប់បរិភោគ
- យំច្រើន
- ឮសម្លេងដែលមិនមានពិតប្រាដក
- ឃើញរូបភាពដែលមិនពិត
- មានគំនិតចង់ធ្វើឲ្យឈឺចាប់ខ្លួនឯង ឬឈឺចាប់ដល់អ្នកដទៃ
- មានគំនិតចង់សម្លាប់ខ្លួន



យើងនិយាយភាសាខ្មែរ

## សូមទូរស័ព្ទរក រដ្ឋា ម៉ាក់ត្តីរ

### ដើម្បីជួយឱ្យបានទទួលសេវាសុខភាពផ្លូវចិត្ត

# 215-413-3100

extension **5156**

Provided by:
Department of Behavioral Health and Intellectual disAbility Services
Arthur C. Evans, Ph.D., Commissioner

DBHIDS
DEPARTMENT of BEHAVIORAL HEALTH and INTELLECTUAL disABILITY SERVICES
Recovery · Resilience · Self-Determination

C·B·H

CITY OF PHILADELPHIA · LIFE · LIBERTY · AND YOU





# LCCPS

LOWELL COMMUNITY
CHARTER PUBLIC SCHOOL

We believe that every child can learn and we hold high expectations for each student. Our mission promotes the celebration of each student's culture and heritage, while building a strong community that supports academic achievement in a caring and joyful environment.

**Features of our educational program:**
យើងមានកម្មវិធីសិក្សាពិសេសៗ ដូចជា :

- **Extended day and year**
  ការសិក្សាមានរយៈពេលយូរ ក្នុងពេលថ្ងៃ និងឆ្នាំ
- No tuition – we are a public school
  បង្រៀនដោយឥតគិតថ្លៃយើងជាសាលារៀនរដ្ឋ
- Gifted and Talented program
  កម្មវិធីសិស្សពូកែ
- Uniform Policy
  សំលៀកបំពាក់ឯកសណ្ឋាន

**LIMITED OPENINGS IN GRADES K-6**
សូមទាក់ទងមកលោកស្រី Deborah Ye Motew ទូរស័ព្ទ (978) 323-0800 លេខភ្ជាប់ 115 ឬ អ៊ីមែល
dmotew@lccps.org

206 Jackson Street • Lowell, MA 01852 • Phone (978) 323-0800 • www.lccps.org

# កម្មវិធីប្រមូលថវិកាជួយជនក្រីក្រ

## គណៈកម្មាធិការសាខាគណបក្សប្រជាជនកម្ពុជាប្រចាំរដ្ឋញូវជឺស៊ី សហរដ្ឋអាមេរិក

### លិខិតថ្លែងអំណរគុណ

ខ្ញុំបាទ សែម សានី ប្រធានសាខាគណបក្សប្រជាជនកម្ពុជាប្រចាំរដ្ឋញ៉ូជឺស៊ី (USA) សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោក លោកស្រី អ្នកនាងកញ្ញា ព្រមទាំងបងប្អូនទាំងអស់ដែលបានចូលរួមក្នុងពិធីជប់លៀង ដើម្បីប្រមូលថវិការ ដើម្បីយកទៅជួយជនក្រីក្រនៅឃុំសំបួរមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ២០១១ កន្លងមកនេះ ។ តាងនាមខ្ញុំបាទជាតំណាងដល់ជនក្រីក្រទាំងអស់ក្នុងស្រុកសំបួរមាស ខេត្តកំពង់ចាម ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅខ្ពង់ខ្ពស់បំផុត និងសូមជូនពរដល់ឯកឧត្តមលោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា បងប្អូនទាំងអស់ឲ្យបានជួបនូវពុទ្ធពរ គ្រប់ប្រការ

ហត្ថលេខា

ប្រធាន សែម សានី



គណកម្មាធិការ NJCPP ប្រចាំសហរដ្ឋអាមេរិក

### បញ្ជីរាយនាមសប្បុរសជន

| | | | | | |
|---|---|---|---|---|---|
| 1 | ឯកឧត្តម ហែម ហេង និងលោកជំទាវ | $ 200.00 | 23 | Kouch Phal | $ 20.00 |
| 2 | Mr. Mour Sam Onn | $ 500.00 | 24 | Savan Chiem & Bopha Chan | $ 35.00 |
| 3 | Mr. Sok Reang | $ 425.00 | 25 | Visith Oum & family | $ 100.00 |
| 4 | Mr. Chea Sarom | $ 100.00 | 26 | Mao Chamroeun & Oeurn Savon | $ 35.00 |
| 5 | Mr. Sok Yuth | $ 100.00 | 27 | Richey and friend | $ 120.00 |
| 6 | Mr. Arnoud & Lisa Swart | $ 200.00 | 28 | Ms. Meas Thaveth | $ 100.00 |
| 7 | Mr. Im Somaly | $ 150.00 | 29 | Mr. Meas Sambath | $ 100.00 |
| 8 | Mr. Chhour Nguon Ly | $ 150.00 | 30 | Mr. Phal San | $ 100.00 |
| 9 | Ms. Vong March | $ 110.00 | 31 | Mr. Casper | $ 50.00 |
| 10 | Stacy Dok Chantha & family | $ 20.00 | 32 | Mr. Say | $ 50.00 |
| 11 | Mr. Sovannkiry (Mekong Video) | $ 100.00 | 33 | Battle | $ 18.00 |
| 12 | Saly | $ 35.00 | 34 | Neang Yoeun & Sao Sokhom | $ 35.00 |
| 13 | Ms. Srey Arm | $ 10.00 | 35 | Yean Yin & Ratha Onn | $ 35.00 |
| 14 | Pech Chhoy | $ 135.00 | 36 | Phay Tong | $ 180.00 |
| 15 | Tha Ry | $ 40.00 | 37 | Reurt & Srey Nena | $ 50.00 |
| 16 | CPP-Rhode Island | $ 100.00 | 38 | Neang Lin | $ 10.00 |
| 17 | Ly Sang Vouch | $ 40.00 | 39 | Charotun | $ 20.00 |
| 18 | Mr. Ieng Sithol | $ 35.00 | 40 | Ray & Leng Keo | $ 100.00 |
| 19 | Sothear Duch | $ 200.00 | 41 | Sinath | $ 40.00 |
| 20 | Saly Chan | $ 100.00 | 42 | Rockha Iem | $ 100.00 |
| 21 | Bophar - Hour | $ 100.00 | 43 | Chanly Var & family | $ 30.00 |
| 22 | Veasna & Sophal | $ 25.00 | 44 | Chea Samath (ស្រួច) | $150.00 |

*សូមប្រសិទ្ធិពរជ័យដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ អោយជួបប្រទះនូវពុទ្ធិពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*ញូវជឺស៊ី ថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១១*

*ប្រធាន សៀកសាន់នី សែម*





តមកពីទំព័រទី ១

# បទសម្ភាសន៍ជាមួយអគ្គលេខា...

ការស្វែងរកពិគ្រោះគ្នា រកយុត្តិសាស្ត្រថ្មីយកទៅដឹកនាំក្នុងប្រទេសពីព្រោះគណបក្សសិទ្ធិមនុស្សតែងតែស្តាប់មតិក្រុមដឹកនាំ ហើយមកហ្វីឡានេះ គឺមកជួបសហព័ន្ធខ្មែរកម្ពុជាក្រោម ។

**ខ្មែរប៉ុស្ដិ៍ :** ការដឹកនាំនយោបាយក្នុងស្រុកតាមរយៈមតិយោបល់អ្នកក្រៅស្រុក តើធ្វើទៅរបៀបណា?

**យ៉ែម ប៉ុញ្ញារិទ្ធ :** យើងដឹកនាំពឹងផ្អែកទៅលើទី១គឺគំនិតស្មារតី. គំនិតជាយុទ្ធសាស្ត្រដែលអាចផ្តត់ផ្គង់ដល់យើងជាបន្ថែម ដើម្បីយកទៅអនុវត្តន៍ ទីពីរគឺមធ្យោបាយដែលអាចចែកចេញជាពីរ គឺធនធានមនុស្ស នឹងសម្ភារៈ ថវិកា ដូច្នេះគណបក្សសិទ្ធិមនុស្សដែលកើតចេញពីការចូលរួមរបស់មហាជនខ្មែរទាំងក្នុងទាំងក្រៅប្រទេស យើងត្រូវការជាទីបំផុតសម្ភារៈ ថវិកានឹងគំនិតស្មារតីដឹកនាំ ។

**ខ្មែរប៉ុស្ដិ៍ :** លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សតែងនិយាយថា ហ្វីឡាដែលហ្វៀតែងផ្តល់ជូនជាជំនួយខ្លាខ្លាំងនឹងច្រើនជាងគេទៅគណបក្សសិទ្ធិមនុស្សនៅកម្ពុជា តើនេះគ្រាន់តែពាក្យបញ្ជោទេ ឬក៏ជាការពិត ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** នេះជាការពិតមួយ ដែលខ្ញុំសូមឆ្លៀតឱកាសថ្លែងអំណរគុណដល់បងប្អូននៅហ្វីឡាដែលហ្វៀនេះ ដែលខិតខំលះបង់លុយកាក់នឹងពេលវេលា ដើម្បីទៅជួយគណបក្សសិទ្ធិមនុស្សឱ្យមានដំណើរការបាន ជាពិសេសការចុះទៅរៀបចំវេទិកាសាធារណៈទៅរៀបចំប្រជាពលរដ្ឋតាមមូលដ្ឋានតាមខេត្ត តាមតំបន់ឆ្ងាយៗឱ្យបានកាន់តែច្រើនឡើង ។

**ខ្មែរប៉ុស្ដិ៍ :** សកម្មភាពច្រើននៃគណបក្សប្រឆាំងតែងតែមានសញ្ញាថា មានភាពគ្រោះថ្នាក់កាន់តែច្រើនដល់សមាជិកគណបក្សប្រឆាំងនោះ តើសមាជិកគណបក្សអស់លោក មានទទួលការរងគ្រោះអ្វីទេ ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** ការចុះទៅរៀបចំវេទិកាម្តងៗពេលខ្លះក៏យើងអាចរៀបចំបានសមរមតាមបែបបទលទ្ធិប្រជាធិបតេយ្យ តែកន្លែងខ្លះទៀតក៏ត្រូវទទួលការហាមឃាត់ពីអាជ្ញាធរមូលដ្ឋាន រឿងមួយទៀត គឺយើងរៀបចំទីកន្លែងបានហើយ គេរៀបចំរបស់គេកន្លែងមួយទៀត នៅក្បែរយើង ដោយគេចាក់ធុងបាស់ ឬមេក្រូរំខានយើងមិនឱ្យស្តាប់មតិយោបល់ពលរដ្ឋក្នុងតំបន់បាន ។

**ខ្មែរប៉ុស្ដិ៍ :** តើករណីកើតរបៀបនេះ ដោយសារគណបក្សលោកពុំមានមនុស្សផ្លូវការណ៍ក្នុងឃុំ-សង្កាត់នៅឡើយតើមែនទេ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** ការគៀបសង្កត់នេះ គឺធ្វើឡើងដោយអាជ្ញាធរមូលដ្ឋានមកលើគណបក្សសិទ្ធិមនុស្សដែលបានកើតឡើងឆ្នាំ២០០៧ ដែលយើងពុំទាន់បានចូលរួមក្នុងការបោះឆ្នោតឃុំ-សង្កាត់ម្តងនៅឡើយ បច្ចុប្បន្នយើងនឹងរៀបចំខ្លួនចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ថ្ងៃទី៣ខែមិថុនាឆ្នាំ២០១២ខាងមុខនេះហើយ ។

**ខ្មែរប៉ុស្ដិ៍ :** តើគណបក្សសិទ្ធិមនុស្សអាចមានលទ្ធភាពដាក់បេក្ខជនរបស់ខ្លួនបានច្រើនកន្លែងទេ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** យើងមានបេក្ខជនដាក់ឱ្យឈរឈ្មោះតាមខេត្តនានា ហើយនឹងខិតខំឱ្យបានច្រើនកន្លែងជាទីបំផុត ។

**ខ្មែរប៉ុស្ដិ៍ :** នៅឱកាសបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២នេះ នឹងមានការរួមដៃគ្នាពីគណបក្ស សម រង្ស៊ី ដែរ ឬទេ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** មកទល់ពេលនេះយើងបានព្យាយាមជជែកស្វែងរកការរួបរួមគ្នាជាមួយគណបក្ស សម រង្ស៊ី តែមិនទាន់បានផ្លែផ្កានៅឡើយទេ យើងសង្ឃឹមថា ពីពេលនេះទៅដល់ពេលបោះឆ្នោតក្រែងមានពន្លឺខ្លះ តែឥឡូវនេះងងឹតសូន្យឈឹង ។

**ខ្មែរប៉ុស្ដិ៍ :** គណបក្សហ៊្វុនស៊ិនប៉ិច នឹងគណបក្សនរោត្តមរណឫទ្ធិ កំពុងស្ថិតក្នុងជួរជាគណបក្សប្រឆាំងឬគណបក្សរដ្ឋាភិបាល?

**យ៉ែម ប៉ុញ្ញារិទ្ធ :** សេចក្តីប្រកាសរបស់គណបក្សហ៊្វុនស៊ិនប៉ិចក៏ដូចជាគណបក្សនរោត្តមរណឫទ្ធិ និយាយថា ពួកគេជាគណបក្សដៃគូររបស់រដ្ឋាភិបាល ហេតុនេះហើយបានជាសកម្មជនរបស់គណបក្សទាំងពីរបានងាកមករកគណបក្សសិទ្ធិមនុស្សវិញនៅគ្រប់ទីកន្លែង-គេថាខ្លួនគេជាគណបក្សដៃគូររដ្ឋាភិបាល ក៏ប៉ុន្តែគ្រាន់តែជាគណបក្សរណបប៉ុណ្ណោះ ។

**ខ្មែរប៉ុស្ដិ៍ :** លោកបានលើកឡើងមុននេះបន្តិចពីស្ថិតិស្តីអំពីប្រជាប្រិយភាពរបស់គណបក្សសិទ្ធិមនុស្ស ដោយអង្គការមួយដែលគួរឱ្យជឿបានតើតាមរយៈ ឯកសារនោះបានផ្តល់ប្រជាប្រិយភាពឱ្យគណបក្សសិទ្ធិមនុស្សបានប៉ុណ្ណា?

**យ៉ែម ប៉ុញ្ញារិទ្ធ :** គណបក្សសិទ្ធិមនុស្សពេលកើតឡើងឆ្នាំ២០០៧ មានការគាំទ្រចំនួន២០ម៉ឺនសម្លេង មួយឆ្នាំក្រោយមកពេលបោះឆ្នោតខែមិថុនាឆ្នាំ២០០៨ ទទួលបានសម្លេង៤០ម៉ឺនសម្លេង ក្រោយមកយើងបានខិតខំផ្សព្វផ្សាយការងារ នឹងគោលជំហរនយោបាយមានអង្គការអាមេរិកាំង **តទៅទំព័រទី ៩**


## ត្រូវការអ្នកស្ម័គ្រចិត្ត!

**តើលោកអ្នកចង់ស្ម័គ្រចិត្តជួយស្ត្រី នៅក្នុងសហគមន៍របស់លោកអ្នកទេ?**

**តើលោកអ្នកជាស្ត្រីខ្មែរ ចន្លោះអាយុពី ៤០ ទៅ ៦៥ ឆ្នាំមែនទេ?**

SEAMAAC គឺកំពង់ស្វែងរកស្ត្រីដែលស្ម័គ្រចិត្តចង់ជួយបណ្តុះបណ្តាល សំរាប់កម្មវិធីសុខភាព សុដន់របស់យើង ។

កិច្ចការរួមមាន:

- កត់សំគាល់មិត្តភ័ក្តណាដែលអាចចូលរួមក្នុងកម្មវិធីនេះបាន
- អញ្ជើញមិត្តភ័ក្តទៅចូលរួមក្រុមការសិក្សាអំពីសុខភាពសុដន់
- ដឹកនាំក្រុមជាមួយបុគ្គលិក SEAMAAC (រៀងរាល់ 1-2 ខែម្តង)
- ធ្វើការរំលឹកក្រុមតាមទូរស័ព្ទ
- សកម្មភាពទាំងនេះនឹងប្រើពេល ប្រហែល 5-6ម៉ោង រៀងរាល់ខែនិមួយៗ ។

**ដោយការអរគុណ យើងខ្ញុំឧបត្ថម $100 ក្នុងពេល ៣ ខែនេះ សំរាប់លោកអ្នកបានស្ម័គ្រចិត្តក្នុងតួនាទីនេះ ។**

ប្រសិនបើលោកអ្នកចាប់អារម្មណ៍ សូមទាក់ទងមក **កញ្ញា** Amy Jones

at 215-467-0690 ext. 14 or **កញ្ញា** Lan Banh at ext. 39

1711 South Broad Street – Philadelphia, PA 19148

SEAMAAC





# មន្ទីរសុខភាព ART OF WELLNESS CENTER

647 Bainbridge St. Phila PA., 19147 215-305-2238

ទទួលព្យាបាលខ្លួន និងបញ្ហាផ្លូវចិត្តប្រើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នកដោយប្រើរបៀបបច្ចេកទេសអាស៊ីនិងបច្ចេកវិទ្យាបស្ចិមប្រទេស ។

ទទួលព្យាបាលគ្រប់វិស័យ

• ប្រើម្ជុលគគថ្នាំ • ចាប់សរសៃ • ចិត្តវិទ្យា • យោគ/ភាវនា

TREATMENT TYPE

• Acupuncture • Acupressure • Psychotherapy • Yoga/ Meditation



www.artofwellnesscenter.com

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម :

| | | | |
|---|---|---|---|
| • Weight Management for Adult & Children | • គ្រប់គ្រងទម្ងន់សម្រាប់ចាស់និងក្មេង | • Insomnia (Difficulty Sleeping) | • ដេកមិនលក់ |
| • Diabetes | • ទឹកនោមផ្អែម | • Feeling Tired & Weak | • អស់កម្លាំង មិនស្រួលខ្លួន |
| • High Blood Pressure | • លើសសម្ពាធឈាម | • Stress /Anxiety | • ភាពតានតឹង/ការថប់អារម្មណ៍ |
| • High Cholesterol Level Issue | • លើសកំរិត កូលេសស្តេរ៉ូល | • Depression | • ធ្លាក់ទឹកចិត្ត |
| • Pain Management | • ឈឺខ្លួនប្រាណគ្រប់កន្លែង | • Family Issues | • មានវិបត្តិក្នុងគ្រួសារ |
| • Nutrition Consultation (Free) | • ពិគ្រោះពីម្ហូបអាហារ ( មិនយកកំរៃ) | • Addiction Issues | • ការញៀន និងអ្វីមួយ |
| • Women´s Health | • សុខភាពស្ត្រី | • Anger Management | • មានកំហឹងច្រើន |

យើងទទួលយក AETNA នឹង UNITED HEALTHCARE CIGNA

តមកពីទំព័រទី ១

## ការិយាល័យសេវាសុខភាពចរិយា...

ទៅវិញទេ ។ អំពើហិង្សា ដែលគេច្រើនភ្ជាប់ទៅនឹងវិបត្តិសុខភាពផ្លូវចិត្ត គឺមិនមែនធ្វើឡើងចំពោះអ្នកដទៃទេ...តែធ្វើចំពោះខ្លួនឯងទៅវិញ។

នៅពេលដែលបុគ្គល និងសហគមន៍ប្រឈមមុខនឹងព្រឹត្តិការណ៍ ដ៏តក់ស្លុតដូច្នេះ គេច្រើនមានអារម្មណ៍ទុក្ខព្រួយ ឬក៏មានប្រតិកម្មច្រើនយ៉ាងទៅនឹងព្រឹត្តិការណ៍ នេះជាធម្មតាទេដែលអ្នកមានការបារម្ភពីសុវត្ថិភាពក្នុងគ្រួសារអ្នក គេច្រើនមានអារម្មណ៍កំសត់ក្នុងចិត្ត មានទុក្ខព្រួយ ឬក៏អន់ចិត្ត តែទោះបីជាមានអារម្មណ៍តឹងតែងយ៉ាងណាក៏ដោយ អ្នកទាំងនោះតែងតែបានសះស្បើយមកវិញ ។ ការទទួលស្គាល់នូវអារម្មណ៍របស់ខ្លួន ហើយនិយាយទៅប្រាប់អ្នកដែលគាំទ្រណាម្នាក់ ដែលមិនវាយតម្លៃថាល្អឬអាក្រក់ ជាមិត្តភ័ក្រ្ត ជាសមាជិកសហគមន៍ ឬក៏ជាអ្នកដែលនៅស្ថាប័ននៃជំនឿសាសនា ដូចជាព្រះសង្ឃ អាចមកជំនួយយ៉ាងប្រសើរ ។ បន្ថែមពីការនិយាយប្រាប់អំពីអារម្មណ៍របស់អ្នក នៅមានអំពើមួយចំនួនទៀតដែលអ្នកអាចធ្វើបាន ដើម្បីជាជំនួយដល់សុខភាពផ្លូវកាយនិងផ្លូវចិត្ត ដូចជាដេកឱ្យបានគ្រប់គ្រាន់ ធ្វើការអ្វីដែលអ្នកចូលចិត្ត ហើយយកពេលដើម្បីស្វែងរកកម្លាំងថ្មី ដូចជាធ្វើសម្មាធិសូត្រធម៌ ជួយដល់អ្នកដែលត្រូវការជំនួយ ក៏អាចមកជាជំនួយដល់សុខភាពកាយនិងចិត្តរបស់អ្នកដែរ។

មានមនុស្សមួយចំនួន មានការលំបាកនឹងជាសះស្បើយ ពីព្រឹត្តិការណ៍តក់ស្លុតទាំងនោះ ពីព្រោះអ្នកទាំងនោះធ្លាប់ជួបប្រទះព្រឹត្តិការណ៍តក់ស្លុតនោះពីពេលមុនមក ហើយកំពុងប្រឈមមុខនឹងភាពតប់ប្រមល់នៅឡើយ ឬមិនមានការគាំទ្រពីគ្រួសារឬមិត្តភ័ក្រ្តទេ ដូច្នេះគួររកជំនួយពីអ្នកពិគ្រោះយោបល់ ឬអ្នកឯកទេសខាងសុខភាពផ្លូវចិត្ត អាចជួយគ្រប់គ្រងភាពតប់ប្រមល់ ដើម្បីឱ្យសុខភាពផ្លូវកាយនិងផ្លូវចិត្តបានប្រសើរឡើង។

ប្រសិនបើរូបអ្នកឬមាននរណាម្នាក់មានបំណងធ្វើបាបខ្លួនឯង ឬក៏បំណងធ្វើបាបដល់អ្នកដទៃ ស្វែងរកវិធីធ្វើអ្វីអាក្រក់ដល់ខ្លួនឯង និយាយឬសរសេរពីស្លាប់ ឬលាលោក ឬសម្លាប់ខ្លួនអារម្មណ៍ខឹងឆេវឆាវដែលឥតទប់បាន ឬបំណងចង់ សងសឹក ឬបង្ហាញសញ្ញាតប់ប្រមល់ច្រើនដងក្នុង មួយថ្ងៃ ឬ១អាទិត្យ ដូច្នេះ អ្នកអាចរកជំនួយបានដោយហៅរកទូរស័ព្ទ លេខបន្ទាន់ទប់ស្កាត់អំពើសម្លាប់ខ្លួន (800-237-Talk )។ អ្នកអាចទៅរកគ្រូពេទ្យ ឬ "Crisis Response Center" ឬទៅកន្លែងព្យាបាលដោយផ្ទាល់។

ចាប់ពី៦ឆ្នាំចុងក្រោយនេះមក DBHIDS បានប្តូរប្រព័ន្ធសុខភាពទាំងអស់ក្នុងការព្យាបាលមនុស្សចាស់នឹងកូនក្មេង ហើយខិតខំបង្កើនគុណភាពសុខភាពនិងសុខុមាលភាព ជូនពលរដ្ឋហ្វីឡាដែលហ្វៀ ។ បង្កើនគុណភាព និងការពារសុខភាព គឺជាមធ្យោបាយដ៏ប្រសើរបំផុត សំរាប់ការពារកុំឱ្យមានសោកនាដកម្មទៅថ្ងៃមុខបាន ។DBHIDS ចេញទៅជួប ចូលរួម នឹងមានសកម្មភាពការពារ ដើម្បីពង្រឹងធនធានក្នុងតំបន់ ដើម្បីជាជំនួយដល់ការព្យាបាល និងកាត់បន្ថយស្លាកស្នាមអាក្រក់ ដើម្បីធានាឱ្យបុគ្គលគ្រប់រូប និងគ្រួសារ អាចទទួលជំនួយដែលខ្លួនត្រូវការបាន។

DBHIDS សហការណ៍ជាមួយសហគមន៍ទាំងអស់ ដើម្បីសម្រួលការចូលទៅប្រើប្រាស់សេវានិងការគាំទ្រ ហើយកសាងលំនឹងរបស់សហគមន៍ ។ យើងបានសហការណ៍ជាមួយនឹងសហគមន៍ អាស៊ីអាគ្នេយ៍ តាំងពីច្រើនឆ្នាំកន្លងមកដើម្បីបុព្វហេតុទាំងនោះ ។ បុគ្គលិកក្រសួងយើងទទួលស្គាល់ថាមានរនាំងខ្លះៗ រារាំងការព្យាបាលវិជ្ជាជីវៈ ដូចជារនាំងភាសាសំរាប់ទាក់ទង រនាំងវប្បធម៌ ដែលត្រូវការព្យាបាលតាមបែបរបស់ខ្លួន ។ ការចូលរួចធ្វើការជាមួយសហគមន៍ អាស៊ីអាគ្នេយ៍ គឺរាប់បញ្ចូលកម្លាំងការងារ ទទួលអាហារពេលព្រឹកជាមួយព្រឹទ្ធាចារ្យ បង្កើតការនិយាយរឿងក្នុងចំណោមកុមារនិងមនុស្សពេញវ័យ យកអ្នកព្យាបាលធ្វើជាអ្នកអប់រំនឹងជំនួយវប្បធម៌ សហការណ៍ជាមួយអ្នកព្យាបាលក្នុងតំបន់ និងស្ថាប័នជំនឿសាសនា បញ្ចូលគ្រូពេទ្យគ្រួសារ ព្យាបាលជម្ងឺចរិយា និងព្យាបាលតាមទំនៀមទំលាប់ និងជួយឱ្យមាន"ក្រុមព្យាបាលចល័ត"។

នៅមានការងារមួយទៀតរបស់ DBHIDS គឺសហការណ៍ជាមួយក្រសួងប៉ូលីសហ្វីឡាដែលហ្វៀ ដើម្បីហ្វឹកហ្វឺន ក្នុងប្រតិបត្តិការណ៍ពេលមានវិបត្តិ "Crisis" ឱ្យស្គាល់នឹងឆ្លើយតបបានប្រសើរចំពោះសមាជិកសហគមន៍ ដែលមានវិបត្តិសុខភាពចរិយា ។ នៅរដូវរងារខាងមុខ DBHIDS នឹងផ្តើមនាំមកជូន ហ្វីឡាដែលហ្វៀ នូវការហាត់ហ្វឹកហ្វឺន ពី"ជំនួយដំបូងដល់សុខភាពផ្លូវចិត្ត"។ ការសិក្សាដែលគេទទួលស្គាល់ជាអន្តរជាតិ និងជួយដល់អ្នកដែលមិនមែនព្យាបាលជម្ងឺផ្លូវចិត្តវិជ្ជាជីវៈ និងពលរដ្ឋទូទៅ ឱ្យអាចសំគាល់ យល់ និងឆ្លើយតបទៅនឹងសញ្ញានៃជម្ងឺវិបត្តិផ្លូវចិត្ត និងវិបត្តិពីគ្រឿងស្រវឹង ។DBHIDS មានសេចក្តីរីករាយនឹងប្រកាសពីកិច្ចប្រជុំឆ្នាំទី៦ ស្តីអំពី "The Faith and Spiritual Affairs" នៅថ្ងៃទី December 12, 2011 ។

DBHIDS នឹងបន្តការគាំទ្រគ្រប់ស្រទាប់របស់ខ្លួន ចំពោះប្រតិបត្តិការណ៍លើកិច្ចការពារ និងកិច្ចគាំទ្រដល់សេវាជូនដល់បុគ្គល ដល់គ្រួសារ ដល់កុមារ ដល់យុវជន និងដល់សហគមន៍ ដើម្បីទប់ស្កាត់ព្រឹត្តិការណ៍ដ៏គួរឱ្យតក់ស្លុតនៅពេលអនាគត ដោយចិញ្ចឹមសេចក្តីសង្ឃឹម ព្យាបាលនឹងជាសះស្បើយ ។ យើងនៅទីនេះរង់ចាំជួយ បើលោកអ្នកត្រូវការ។

By Arthur C. Evens

បកប្រែប្រែសម្រួលដោយ : ខ្មែរប៉ុស្តិ៍

Continued from page 1

## The City of Philadelphia ...

increased during an episode of psychosis and when combined with substance use. Research demonstrates that behavioral health challenges contribute very little to overall rates of violence, and most people with behavioral health challenges are not violent. In reality, some studies have found that people with mental health challenges are more likely to be victims of violence. The most common form of violence assosciaed with behavioral health challenges is not against others, but rather, against oneself.

When individuals and communities are exposed to a traumatic event, it is common to experience feelings of stress or a variety of reactions to the event. It is normal to feel anxious about individual and your family's safety. People also experience sadness, grief, and anger. Although people often have intense feelings after a traumatic event, they typically recover. Acknowledging your feelings and talking to a supportive, non-judgmental family member, friend, community member, or someone associated with a faith-based institution such as a clergy member can be helpful. In addition to talking about your feelings, there are other things you can do to promote physical and emotional health. Getting adequate sleep, doing activities you enjoy, and taking time to renew your spirit through meditation, prayer, or helping others in need can also help to promote physical and emotional health.

Some people may have more difficulty recovering from a traumatic event. This is more likely to occur among individuals who have had previous traumatic experiences, who are faced with ongoing stress, or who lack support from friends and family. Getting help from a counselor or mental health professional can help us manage stress while improving our mental and physical health.

If you or someone you know threatens to harm him/herself or another person; looks for ways to harm him/herself; talks or writes about death, dying or suicide; feels rage, uncontrolled anger, or desires revenge; or shows signs of considerable stress for several days or weeks, GET HELP by calling the suicide prevention hotline (800-273-TALK). A person could also visit a health care provider or crisis response center, or identify a treatment location (information on how is provided at the end of this article).

For the past six years, DBHIDS has been radically transforming its system of care to focus on recovery for adults and resilience for children. DBHIDS strives to improve the health and well-being of all Philadelphians. Health promotion and early intervention is the best way to prevent future tragedies. DBHIDS achieves this through a wide variety of ongoing outreach, engagement, and prevention activities to strengthen local resources, to promote recovery and resilience, and to reduce stigma to ensure that individuals and families receive professional help when needed. DBHIDS promotes care that is individualized, culturally competent, holistic, trauma-informed and evidence based, and inclusive of families, peers, and communities. People can and do recover from behavioral health challenges and substance-related conditions.

DBHIDS partners with diverse communities to improve access to services and supports and to build upon community strengths. DBHIDS has partnered with the Southeast Asian community for the past several years to achieve this aim. Department staff recognize potential barriers to accessing professional care, including communication barriers, as well as cultural preferences for types of care. Collaboration with the Southeast Asian community has included participation in the Southeast Asian Task Force, hosting jook breakfasts for older individuals, promoting the use of storytelling among children and adults, using clinicians as educators and cultural helpers, partnering with local healers and faith-based institutions, integrating primary care, behavioral healthcare and traditional healing approaches, and supporting the availability of mobile out patient teams.

Other related DBHIDS initiatives include a partnership with the Philadelphia Police Department to train members in crisis intervention to better recognize and effectively respond to community members with behavioral health challenges. Beginning this winter, DBHIDS will bring Mental Health First Aid Training to Philadelphia. This internationally recognized training helps nonmental health professionals and the general public to identify, understand, and respond to signs of mental health challenges and substance -related conditions. DBHIDS is also pleased to announce the Faith and Spiritual Affairs 6th Annual Conference on December 12, 2011. Information on these initiatives is available on the DBHIDS website.

DBHIDS will continue to support a broad array of treatment, intervention, prevention, and support services to individuals, families, children, youth and communities to prevent future traumatic events while fostering hope, healing, and recovery. We are here to help if needed.

**Background Information.** *Arthur C. Evans Jr., Ph.D. is the Commissioner of the Phila delphia Department of Behavioral Health and Intellectual disAbility Services (DBHIDS). DBHIDS is comprised of the Office of Mental Health (OMH), the Office of Ad- diction Services (OAS), Intellectual dis Ability Services (IDS), and Community Behavioral Health (CBH), which manages behavioral health and intellectual disability services in Philadelphia. For additional in formation, please visit us online at: www. DBHIDS.org or call us at 215-685-5400 (Office of Mental Health). The Philadelphia Network of Care and Supports website (www.philly.networkofcare.org) includes information that can help you or your loved ones connect to services and supports in the Philadelphia area.*



# ចូរធ្វើចលនា!

មួយភាគបីនៃក្មេងៗ ប្រឈមមុខចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរខ្លាំងណាស់ ដោយព្រោះតែធាត់ពេក ។ យើងអាចជួយកូនរបស់អ្នកឲ្យជៀសវៀង ជាមួយនឹង :

- ការចូលជាសមាជិកនៅមណ្ឌលហាត់ប្រាណ
- អត្ថប្រយោជន៍ Weight Watchers® របស់យើង (សំរាប់ក្មេងៗ អាយុ 10+)
- ការប្រឹក្សាខាងអាហារមានជីវជាតិ

CHIP បាននាំមកជូនអ្នកដោយ KidzPartners មានផ្ដល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេង ជំទង់ៗ ដែលគ្មានការធានារ៉ាប់រង ។ ថែមទាំងអត្ថប្រយោជន៍ដែល អាចនាំឲ្យមានសុខភាពល្អអស់មួយជីវិត ។

## ចូរដាក់ពាក្យសុំនៅថ្ងៃនេះ!
## 1-888-888-1211

TTY 1-877-454-8477

chip Pennsylvania's Children's Health Insurance Program
យើងរ៉ាប់រងក្មេងៗទាំងអស់។

KidzPARTNERS
ជំរោងសំរាប់ក្មេងៗរបស់ HEALTH PARTNERS

www.chipcoverspakids.com www.kidzpartners.com



# ការតាំងពិព័ណស្តីអំពីសុខភាពសំរាប់ព្រឹទ្ធាចារ្យខ្មែរ ដែលមានអាយុពី ៥៥ ឆ្នាំ ឡើងទៅ

**FREE EVENT**
FOR CAMBODIAN SENIORS (55+)
**KHMER LANGUAGE**

មានការណែនាំអំពីការថែទាំសុខភាព
មានការពិនិត្យសុខភាពផ្សេងៗ
ការផ្ដល់ព័ត៌មានសំខាន់ៗដែលមានផលប្រយោជន៍សម្រាប់ព្រឹទ្ធាចារ្យ
ការផ្ដល់ព័ត៌មានអំពីអ្វីដែលព្រឹទ្ធាចារ្យអាចមានសិទ្ធទទួល
មានអំណោយចែកជូន
មានអាហារពេលព្រឹកនិងអាហារថ្ងៃត្រង់ជូនពិសា



**មានឡានមកទទួលបីកន្លែង ពត៌មានបន្ថែម សូមទាក់ទងនិង:**

ង៉ែត កន ២១៥-៩២១-៥៥២៩

អ៊ូ កៅ ២១៥-២៧៧-៥៨៩៣

សមាគមខ្មែរ ២១៥-៣២៤-៤០៧០

ថ្ងៃសៅរ៍ ទី ១៥ ខែ តុលា ឆ្នាំ ២០១១
ទីកន្លែង: វត្តព្រះពុទ្ធរង្សី
អាស័យដ្ឋាន: 2400 South 6th Street, Phila., PA 19148
ចាប់ពីម៉ោង ១០ ព្រឹក ទៅដល់ម៉ោង ២:០០ រសៀល

**ពិធីនេះឧបត្ថម្ភដោយ:**

វត្តព្រះពុទ្ធរង្សី
សមាគមព្រឹទ្ធាចារ្យខ្មែរហ្វីឡាដែលហ្វៀ

សមាគមខ្មែរនៅមហានគរហ្វីឡាដែលហ្វៀ
CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.

PCA
PHILADELPHIA CORPORATION FOR AGING™



# CAMBODIAN SENIOR HEALTH FAIR

**FREE EVENT**
FOR CAMBODIAN SENIORS (55+)
**KHMER LANGUAGE**

**AT THE HEALTH FAIR**
Lectures by Health Experts
Health Screenings
Information on Senior Benefits
Information on Entitlements
Free Breakfast & Lunch
Special Give Aways



**3 Bus Pick-Up Locations**
**For More Information**

**Kau Our** 215.277.5893
South Philly

**Kan Nget** 215.921.5529
Southwest Philly

**CAGP** 215.324.4070
North Philly

PREAH BUDDHA RANGSEY TEMPLE
SATURDAY OCT. 15 @ 10:00AM - 2:00PM
2400 S. 6TH ST. PHILA., PA 19148

**SPONSORED BY**

**PREAH BUDDHA RANGSEY TEMPLE**
**CAMBODIAN AMERICAN SENIOR ASSOCIATION**

សមាគមខ្មែរនៅមហានគរហ្វីឡាដែលហ្វៀ
CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.

PCA
PHILADELPHIA CORPORATION FOR AGING™

# សម្បត្តិនៃមនុស្សចាស់

ដោយ : ពិន សំខុន

មនុស្សចាស់ស្ទើរតែគ្រប់រូបបានខិតខំកសាងបទពិសោធន៍ ចំណេះដឹង ការចងចាំ ដែលជាសម្បត្តិអរូបិយ ហើយនឹងសម្បត្តិរូបិយ ដែលជាលុយកាក់ ជាផ្ទះសម្បែង ដំណាំដាំដុះ ស្រែចំការ ដ៏ច្រើនឆ្នាំច្រើនខែ មានទាំងក្តៅត្រជាក់ ភ្លៀងទឹកកក ខ្លះក៏ពូនជាសម្បត្តិមហាសាល ខ្លះទៀតមិនមានសល់អ្វីសោះ! សល់ខ្លះដែរ ហោចណាស់ក៏នៅមានញាតិផៅ មិត្តភ្លើម្រាក់រាប់មិនអស់ផងដែរ ។ ក៏ប៉ុន្តែមនុស្សចាស់ខ្មែរជាច្រើន មើលស្រាលទៅលើសម្បត្តិទាំងនោះ ហើយបណ្តោយខ្លួនឱ្យទៅជាមនុស្សគ្មានប្រយោជន៍ ខ្លះទៅជាកាកសំណល់នៃសង្គមក៏មានយ៉ាងគួរឱ្យស្តាយ ។

យាយតាទាំងឡាយអើយ! អ្នកដឹងទេថា មានមាតាបីតាជាច្រើន ស្រក់ទឹកភ្នែក ដោយកូនខ្លួនកើតមកហើយ ពុំមានយាយតា ដែលធ្លាប់តែមានការស្រឡាញ់ថ្នាក់ថ្នមចៅៗ ដោយពុំមានលក្ខខណ្ឌនឹងគេ ។ គឺយាយតា កុមារនោះហើយ ដែលជាអ្នករំលឹកចំណងគ្រួសារមិត្តភ័ក្រ្តដ៏វែងអន្លាយផ្តល់ប្រវត្តិរូបនិងរឿងរ៉ាវនៃអតីតកាលឱ្យដល់ចៅសំឡាញ់ ដោយពុំមាននឿយហត់ ដែលជាបុព្វហេតុនៃការលូតលាស់រូបរាងកាយនឹងសតិបញ្ញារបស់កុមាររាប់ទាំងការយល់សុបិន្តល្អរបស់គ្នាទៀតផង ។ មាននៅសល់ទ្រព្យសម្បត្តិច្រើននៅពេលចូលនិវត្តន៍ជាការប្រសើរហើយ! ពីព្រោះលោកអ្នកបានគ្រោងត្រៀមកុំឱ្យ



I Love My Grandma

មានការខ្វះខាតនៅពេលខ្លួនមានកម្លាំងថមថយធ្វើការមិនបាន នេះជាមេរៀនដំបូងបង្អស់ ដែលលោកអ្នកបង្រៀនចៅៗដែលនឹងក្លាយទៅជាមនុស្សទទួលខុសត្រូវនៅអនាគត ក៏ប៉ុន្តែបើមិនមានសេសសល់អ្វីទៅវិញ ក៏ពុំជាគុណវិបត្តិអ្វីធ្ងន់ធ្ងរដែរ ដោយសារតែយើងពុំមានធ្វើអ្វីរំលោភនឹងច្បាប់រដ្ឋ គឺរដ្ឋនឹងផ្តល់ការឧបត្ថម្ភដល់លោកអ្នកវិញ ឱ្យរស់ជាមនុស្សថ្លៃថ្នូរបានដូចអ្នកឯទៀតដែរ ។ ក្នុងករណីណាក៏ដោយយាយតា គឺជាសម្បត្តិកាត់ថ្លៃមិនបានរបស់កូននិងចៅក្នុងការផ្តល់ភាពរីករាយក្លាកក្លាយក្នុងគ្រួសារ ដែលរុំខ្ចប់ដោយក្តីស្រឡាញ់ ។ សេចក្តីស្រឡាញ់នោះ បានធ្វើឱ្យមនុស្សចាស់ក្លាយជាអមតៈ ពីព្រោះវិទ្យាសាស្ត្របានរកឃើញថា មនុស្សចាស់មានបំណែករបស់ខ្លួនផ្ទាល់ចំនួនពាក់កណ្តាលនៅក្នុងការរីកចំរើនរបស់កូន ហើយនៅពេលមានចៅបំណែករបស់យាយតាតាមទៅមានមួយភាគបួនជាបន្តទៀត មិនចេះចប់ ។ នេះគឺជាចំណងធម្មជាតិនៃការស្រឡាញ់ចង់ឱ្យកូននឹងចៅបានល្អមានបានជាងគេ មានកម្លាំងខ្លាំងក្លាបំផុត...។ល។ ដែលសេចក្តីស្រឡាញនោះនឹងផ្តល់ការលើកតំកើងការលើកស្ទួយការគាំទ្រជាប្រចាំដល់គ្រួសារខ្លួន។

នៅមានទ្រឹស្តីសង្គមខ្មែរខ្លះ បានធ្វើឱ្យចាស់ៗខ្មែរនិយាយថា "អញចាស់ហើយមិនរំខាននរណាទេ អញស្លាប់ទៅ យកខ្មោចអញទៅបោះចោលឯណាក៏បានដែរ" ឬក៏និយាយថា "អញចាស់ហើយ ក្រមិនត្រូវនៅក្បែរកូនចៅនាំឱ្យវាទទួលគំរូអាក្រក់" ឬក៏ចងកំហឹងនឹងកូនចៅរាល់ថ្ងៃ ពីព្រោះកូនចៅមិនជួយគាត់ឱ្យគ្រប់គ្រាន់...។ល។ ការចងកំហឹងការគិតអវិជ្ជមានរបស់យាយតា គឺជាការបន្សាបសេចក្តីស្រឡាញ់ចំពោះកូនចៅដែលគ្នាត្រូវការអារម្មណ៍ល្អនោះ សំរាប់ធាត់ធំ ដូច្នេះគ្មានការអ្វីដែលគួរឱ្យខ្មាស់អៀននៅពេលទទួលស្គាល់ថា "មានកំហុស" ឬក៏ "សុំទោស" ដល់អ្នកដែលយើងបានធ្វើអ្វីឆ្គាំឆ្គងទៅលើឱ្យបានឆាប់ពេលណាប្រសើរពេលនោះភ្លាម។ លោកអ្នកជាយាយតាជាមនុស្សដែលមានរឿងច្រើនណាស់សំរាប់បណ្តុះអារម្មណ៍គ្រួសារថ្មីជាមួយប្រវត្តិពិតដែលគួរណែនាំឱ្យបានជិតនឹងវប្បធម៌នៃការគោរពសីលធម៌ ដែលនៅ ស.រ.អានេះ អ្នកទទួលផលពីផែនដីនៃសំណាងខ្ពស់នោះ គឺអ្នកដែលមានចំណេះដឹងមានសីលធម៌ខ្ពស់នោះឯង។

នៅហ្វីឡាដែលហ្វៀ នៅរូដអាយឡិន ឬនៅឡូវែល ឬតំបន់ឯទៀតៗ ចាស់ៗខ្មែរធ្លាប់បានបង្ហាញខ្លួនជាមន្ត្រីរាជការ ជាអ្នកកាន់កងទ័ព ជាពាណិជ្ជករ ជាកសិករ...។ល។ ដែលសុទ្ធសឹងតែមានលទ្ធភាពច្រើនក្នុងការធ្វើខ្លួនឱ្យទៅជាយាយតាដ៏ប្រសើររបស់កូននឹងចៅដែលជាគុណសម្បត្តិ មិនគួរលាក់លៀម ថ្វីត្បិតតែលោកអ្នកនិយាយភាសាអាមេរិកកាំងមិនបានល្អ ឬមិនមានសម្បត្តិអ្វីក៏ដោយ ។ លោកអ្នកក្រីក្រត្រូវស្វែងរកឱ្យគេជួយ ពីព្រោះវាជាសិទ្ធិលោកអ្នកដែលត្រូវតែមានក៏រិតជីវភាពសមរម្យ រីឯលោកអ្នកវិញក៏ត្រូវបង្ហាញពីភាពទទួលខុសត្រូវក្នុងជីវិត និងសម្រាប់ក្រុមគ្រួសារតបវិញ ក្នុងបច្ចុប្បន្នក៏ដូចជាទៅអនាគត ទោះជាបន្ទាប់ពីមរណភាពទៅហើយក្តី ។ បើលោកអ្នកមិនមែនជាអ្នកមានសម្បត្តិលោកអ្នកអាចទិញ "ការធានារ៉ាប់រងជីវិត" ទុកឱ្យកូនចៅ ទោះជាតិចតួចក៏ដោយក្តីតាមលទ្ធភាពរបស់លោកអ្នក ។ រីឯនៅហ្វីឡាដែលហ្វៀមានវត្តខ្មែរពីរ គឺវត្តព្រះពុទ្ធវង្សី និងវត្តបាលីល័យមានកម្មវិធីមរណសង្គ្រោះដែលអាចផ្តល់លទ្ធភាពងាយស្រួលធ្វើបានដល់ពលរដ្ឋឱ្យអាចធ្វើបុណ្យឈាបនកិច្ច ជូនដល់គ្រួសារយាយតាបានយ៉ាងសមរម្យថ្លៃថ្នូរ ។

(តទៅលេខក្រោយ)


GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN
- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី៣០ ខែកញ្ញា ឆ្នាំ២០១១

## ទឹកជំនន់ធ្វើឱ្យខូចដំណាំស្រូវនៅកម្ពុជាអស់៣ភាគរយ

**ដោយ : ឆន ចាន់ស៊ី និង Paul Vrieze**

THE CAMBODIA DAILY

រដ្ឋមន្ត្រីក្រសួងកសិកម្មបានថ្លែងកាលពីម្សិលមិញថា ទឹកជំនន់បានធ្វើឱ្យខូចដំណាំស្រូវរបស់ប្រទេសកម្ពុជា អស់៣ភាគរយនៅតាមបណ្តាខេត្តតាមបណ្តោយទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប ហើយ៧ភាគរយទៀតក៏កំពុងប្រឈមមុខនឹងការបាត់បង់ដែរ ។

ការប៉ាន់ប្រមាណថ្មីរបស់រដ្ឋាភិបាលក៏បានបង្ហាញផងដែរថា ប្រជាពលរដ្ឋ១៥០.០០០គ្រួសារនៅក្នុងខេត្តចំនួន១០កំពុងរស់នៅក្នុងផ្ទះសម្បែង ដែលជន់លិច ហើយកម្រិតទឹកដែលកំពុងឡើងនេះបានធ្វើឱ្យប្រជាពលរដ្ឋ១៧.០០០គ្រួសារផ្លាស់ទីជម្រក ។

ក្រុមមន្ត្រីបានអះអាងថា ទាំងគ្រួសារដែលត្រូវបានជម្លៀស និងអ្នកដែលកំពុងស្នាក់នៅក្នុងផ្ទះដែលជន់លិចសុទ្ធតែត្រូវការការឧបត្ថម្ភ ។ ទន្ទឹមនឹងនោះដែរអ្នកជំនាញផ្នែកជំនួយក្នុងគ្រាអាសន្នម្នាក់បានប្រមានថា ការបាត់បង់ដំណាំស្រូវនៅទីបំផុតអាចនឹងធ្វើឱ្យក្រុមអ្នកភូមិនៅតាមតំបន់ជនបទជាច្រើនធ្លាក់ទៅក្នុងរង្វង់នៃភាពក្រីក្រ និងបំណុល ។

លោក ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មបានថ្លែងថា ស្រូវចំនួន២៥២.០០០ហិកតានៅទូទាំងខេត្តចំនួន១៤បានជន់លិចដោយ៧២.០០០ហិកតាក្នុងចំណោមនោះត្រូវបានបំផ្លាញរួចទៅហើយ រហូតមកទល់ពេលនេះ ។

លោករដ្ឋមន្ត្រីបានថ្លែងថា "ទឹកជំនន់បានបង្កផលប៉ះពាល់...១០ភាគរយនៃដំណាំស្រូវសរុបក្នុងប្រទេសកម្ពុជា ។ ៣ភាគរយបានខូចខាតគិតត្រឹមថ្ងៃទី២៨ ខែកញ្ញានេះ ហើយនឹងមានការខូចខាតស្រូវច្រើនទៀត" ។

យោងតាមអ្នកជំនាញផ្នែកជំនួយបានឱ្យដឹងថា ស្រូវនឹងខូចប្រសិនបើវាលិចទឹកលើសពី១០ថ្ងៃ ។ ខេត្តមួយចំនួននៅជុំវិញបឹងទន្លេសាបឥឡូវនេះបានជន់លិចអស់រយៈពេលប៉ុន្មានសប្តាហ៍មកហើយ ។ ទោះជាយ៉ាង ណាលោក ច័ន្ទ សារុន បានថ្លែងថា ផលប៉ះពាល់ទូទៅ ដោយសារទឹកជំនន់លើផលិតកម្មស្រូវក្នុងប្រទេសតម្លៃស្រូវ និងបរិមាណនាំចេញនឹងមិនធ្ងន់ធ្ងរពេកទេ ។

លោកបានថ្លែងថា "ខ្ញុំគិតថា វាមិនប៉ះពាល់ធ្ងន់ធ្ងរទេ" ដោយបន្ថែមថា ផ្ទៃដីដាំដុះស្រូវសរុបនៅឆ្នាំនេះ គឺ២. ៤លានហិកតា ។ លោក ច័ន្ទ សារុន បានថ្លែងថា "ខេត្តព្រៃវែង គឺជាខេត្តរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសារទឹកជំនន់ ។ ស្រូវជាង៧១.០០០ហិកតាបានជន់លិច ហើយ២៥.០០០ហិកតាទៀតបានរងការខូចខាត ។ ខេត្តកំពង់ធំក៏រងផលប៉ះពាល់ខ្លាំងណាស់ដែរ" ។ **តទៅទំព័រទី១៥**

## មនុស្ស២៥នាក់ស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ តាមដងផ្លូវអំឡុងពិធីបុណ្យភ្ជុំបិណ្ឌ

**ដោយ : អ៊ាង ម៉េងឡេង**

THE CAMBODIA DAILY

លោក ហ៊ឹម យ៉ាន ប្រធាននាយកដ្ឋានចរាចរណ៍ផ្លូវគោកនៃក្រសួងមហាផ្ទៃបានមានប្រសាសន៍កាលពីម្សិលមិញថា មនុស្ស២៥នាក់បានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវអំឡុងពិធីបុណ្យភ្ជុំបិណ្ឌរយៈពេល៣ថ្ងៃ ដែលបានចាប់ផ្តើមកាលពីថ្ងៃច័ន្ទ គឺស្មើនឹងតួលេខកាលពីឆ្នាំមុនដែរ ។

អំឡុងពិធីបុណ្យនេះ មានគ្រោះថ្នាក់ចរាចរណ៍ចំនួន៧៥ករណី គឺធ្លាក់ចុះពីចំនួន៩៩ករណីក្នុងឆ្នាំ ២០១០ ។ មនុស្ស៩៨នាក់បានរងរបួស គឺធ្លាក់ចុះ២៥នាក់បើប្រៀបធៀបទៅនឹងឆ្នាំមុន ។

យោងតាមលោក សាត គឹមសាន ប្រធាននគរបាលចរាចរខេត្តបាត់ដំបងបានឱ្យដឹងថា ភាគច្រើននៃគ្រោះថ្នាក់ចរាចរណ៍បានកើតឡើងនៅក្នុងខេត្តបាត់ដំបង ដោយមានគ្រោះថ្នាក់ចរាចរណ៍១៧ករណី ហើយមនុស្ស៤នាក់បានស្លាប់ ។

លោក សាត គឹមសាន បានកត់សម្គាល់ថា មានអ្នកស្លាប់តិចជាងឆ្នាំ២០១០ពីរនាក់ ហើយបានបន្ទោសទៅលើការបើកបរក្នុងល្បឿនលើសកំណត់ និងសុរាថាជាមូលហេតុនៃគ្រោះថ្នាក់ទាំងនេះ ។ នៅមុនថ្ងៃបុណ្យនេះ មនុស្ស៤នាក់ក៏បានស្លាប់ផងដែរ នៅពេលដែលរថយន្តក្រុងដឹកអ្នកដំណើរមួយគ្រឿងបានបុកជាមួយគោយន្តមួយគ្រឿងនៅក្នុងខេត្តបាត់ដំបងកាលពីថ្ងៃអាទិត្យ ។

នគរបាលបាននិយាយថា សុរាគឺជាមូលហេតុនៃគ្រោះថ្នាក់នេះ ពីព្រោះមនុស្សគ្រប់គ្នាដែលជិះនៅលើគោយន្តសុទ្ធតែស្រវឹងស្រា ។

មនុស្ស៤នាក់បានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវនៅក្នុងខេត្តកំពង់ចាម នេះបើយោងតាមលោក ឆាយ គឹមសុន ជាស្នងការនគរបាលខេត្តដែលបានបន្ថែមទៀតថា មានគ្រោះថ្នាក់ចរាចរណ៍សរុប ១២ករណី នៅក្នុងខេត្តនេះអំឡុងពិធីបុណ្យភ្ជុំបិណ្ឌ ។

លោក ឆាយ គឹមសុន បានមានប្រសាសន៍ថា គ្រោះថ្នាក់ចរាចរណ៍ទាំងនេះគឺដោយសារតែ "ការធ្វេសប្រហែស និងការបើកបរដោយស្រវឹងព្រមទាំងអ្នកដែលបើកក្នុងល្បឿនហួសកំណត់" ។

នៅក្នុងរាជធានីភ្នំពេញ មានគ្រោះថ្នាក់ចរាចរណ៍ចំនួន៣ករណី ហើយមនុស្ស២នាក់បានស្លាប់ ។ លោក ប៉ែន ឃុន អនុប្រធាននគរបាលចរាចររាជធានីភ្នំពេញបានមានប្រសាសន៍ថា បុរស២នាក់បានស្លាប់នៅពេលដែលរថយន្តមួយគ្រឿងបានបុកជាមួយម៉ូតូរបស់ពួកគេ ។

លោកបានមានប្រសាសន៍ថា "បុរសម្នាក់បានស្លាប់នៅតាមដងផ្លូវ ហើយម្នាក់ទៀតត្រូវបានដឹកទៅកាន់មន្ទីរពេទ្យ ទីដែលជននេះបានស្លាប់" ។

យោងតាមលោក ព្រុំ ចាន់ថុល ប្រធាននគរបាលចរាចរខេត្តកំពង់ធំបានឱ្យដឹងថា នៅក្នុងខេត្តកំពង់ធំ មានគ្រោះថ្នាក់ចរាចរណ៍ចំនួន១១ករណីចាប់ពីថ្ងៃទី២៦ កញ្ញា ដល់ថ្ងៃទី២៨ ខែកញ្ញា ។

លោកបានមានប្រសាសន៍ថា "បុរសម្នាក់បានស្លាប់ និង១០នាក់ទៀតបានរងរបួស ។ មួយចំនួនក្នុងចំណោមពួកគេបើកបរដោយធ្វេសប្រហែស ហើយមួយចំនួនទៀតស្រវឹងស្រា" ។

តាមធម្មតា គ្រោះថ្នាក់ចរាចរណ៍កើនឡើងអំឡុងរយៈពេលបុណ្យភ្ជុំបិណ្ឌ នៅពេលដែលប្រជាពលរដ្ឋខ្មែរជាច្រើនធ្វើដំណើរទៅស្រុកកំណើតតាមបណ្តាខេត្តដើម្បីប្រារព្ធពិធីបុណ្យជាមួយក្រុមគ្រួសាររបស់ខ្លួន ៕

## Flooding Destroys 3% of Nation´s Rice Crop

**By Chhorn Chansy And Paul Vrieze**

THE CAMBODIA DAILY

Three percent of the country´s rice crops have been destroyed by flooding in provinces along the Mekong River and around the Tonle Sap lake, and another seven percent is at risk of being lost, the minister of agriculture said yesterday.

New government estimates also show that 150,000 families in 10 provinces were living in flooded homes and rising water had displaced 17,000 families.

Both evacuated families and many of those who are staying in flooded homes are in need of support, officials said, while an emergency aid expert warned that the loss of rice crops could ultimately push many rural villagers into a cycle of poverty and debt.

Agriculture Minister Chan Sarun said 252,000 hectares of paddy fields across 14 provinces were inundated with floodwater, 72,000 hectares of which had already been destroyed.

"Flooding has effected...10 percent of the country´s total rice crop, three percent... was destroyed as of September 28, but more rice will be damaged," Mr Sarun said.

Rice fields are damaged if they are flooded for more than 10 days, according to aid experts. Some provinces around the Tonle Sap have now been flooded for weeks.

However, Mr Sarun said the overall impact of flooding on national rice production, rice prices and export volumes would be limited.

"I think it´s not strongly effected," he said, adding that the total area planted with rice this year was 2.4 million hectares.

"Prey Veng is the worst affected province by the flooding. More than 71,000 hectares [of paddy] is flooded, and 25,000 hectares is destroyed there. Kompong Thom is also bad," Mr Sarun said.

The National Committee for Disaster Management yesterday released its first update on the overall impact of the disaster since Monday, but details were still scarce.

Keo Vy, deputy director of the disaster committee´s information department, said 15 provinces in total had suffered from flooding, while preliminary reports showed that "150,000 families in 10 provinces are effected by flooding alone and 17,000 families were evacuated to safe higher grounds."

"The evacuated families need emergency aid," he said.

Previously, the committee had reported that about 90,000 families were effected and 13,000 households displaced.

Cambodian Red Cross Deputy Secretay-General Men Neary Sopheak said that evacuated families many of whom are stranded in large groups on hills or highlying pagodas and schools need emergency aid such as food, shelter, drinking water and sanitation, while those stuck in flooded homes mostly require food supplies.

"Food is the biggest need. Water, sanitation and [disinfectant] chloramines is an additional need," she said.

On Wednesday, the Cambodian Red Cross reported that the number of evacuated and flooded households in need of help to taled 37,300 families in five provinces alone. Kratie authorities have said another 1,400 families were evacuated there.

Ms Neary Sopheak said that as the Mekong floodwaters recede in the northeast and move south of Phnom Penh, reports were coming in that flooding in Prey Veng and Kandal provinces was worsening,Continued from page08

while Takeo and Svay **Continued to page15**

## Road Accidents Kill 25 People During Pchum Ben Festival

**By Eang MengLeng**

THE CAMBODIA DAILY

Twenty-five people died in road accidents during the three-day Pchum Ben holiday that began Monday, the same number as last year, Him Yan, director of the road traffic department at the Ministry of Interior, said yesterday.

During the festival, there were 75 traffic accidents, down from 99 in 2010. Ninety-eight people were injured, a drop of 25 people compared to last year.

The majority of the accidents occurred in Battambang province, with 17 accidents and four deaths, according to Battambang provincial traffic police chief Sath Kimsan.

Mr Kimsan noted that there were two fewer fatalities than in 2010, and blamed speed and alcohol for the crashes.

Just ahead of the holiday, four people were also killed when a passenger bus collided with a tractor in Battambang on Sunday. Police said alcohol played a factor in the crash, as everyone riding on the tractor had been drinking.

Four people died in road accidents in Kompong Cham province, according to deputy provincial police chief Chay Kimson, who added that there had been a total of 12 accidents in the province during Pchum Ben.

The accidents were due to "careless and drunk drivers, as well as people speeding," Mr Kimson said.

In Phnom Penh, there were three accidents and two fatalities. Two men were killed when a car crushed their motorbike, said Pen Khun, Phnom Penh deputy traffic police chief.

"One man died on the road, and the other was taken to the hospital, where he died," he said.

In Kompong Thom province, there were 11 accidents between Sept 26 and Sept 28, according to Prum Chanthoul, provincial traffic police chief. "One man died and 10 were injured. Some of them were driving carelessly and some were drunk," he said.

Traffic accidents usually spike during the Pchum Ben holiday period, when many Cambodians travel back to their provincial hometowns to celebrate with their families.

តមកពីទំព័រទី ៤

# បទសម្ភាសន៍ជាមួយអគ្គលេខាធិការគណបក្សសិទ្ធិ...

ឈ្មោះ IRI បានធ្វើការស្ទាបស្ទង់មតិ ហើយផ្សាយថា គណបក្សយើងមានការគាំទ្រពិតប្រាកដជិត១លាន សម្លេងដែលគិតជាភាគរយ គឺកើនឡើង១៤ភាគរយ លើសពីនេះ ទៅទៀតនៅមានសម្លេង៣៦ភាគរយ ដែលថា គាំទ្រគណបក្សសិទ្ធិមនុស្ស និងគណបក្សឯទៀតផងដែរ គេនឹងយកទៅពិចារណា។

**ខ្មែរប៉ុស្តិ៍ :** បើសិនជាមានការបោះឆ្នោតគាំទ្រគណបក្សសិទ្ធិមនុស្សចំនួន១៤ភាគរយមែន នឹងបានអាសនៈសភាចំនួនប៉ុន្មាន ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** យោងតាមស្ថិតិនោះ យើងអាចបានអាសនៈនៅសភា ពី៩ទៅ១០អាសនៈ នេះជាស្ថិតិគេបានធ្វើនៅឆ្នាំ២០១០និងនៅឆ្នាំ២០១១នេះ ។

យើងពុំទាន់ទទួលលទ្ធផលថ្មីនៅឡើយទេ ពីព្រោះនៅក្រោយពីស្ថិតិនោះមកយើងបានធ្វើសកម្មភាពច្រើនបំផុតសំដៅទៅមូលដ្ឋាន គឺ "សិទ្ធិមនុស្សដើម្បីផ្លាស់ប្តូរ" ដែលយើងទៅស្តាប់ប្រជាពលរដ្ឋផ្តល់ផ្តែថា នឹងឱ្យយើងប្តូរនយោបាយទៅជាបែបណា !

**ខ្មែរប៉ុស្តិ៍ :** នៅពេលមុនបោះឆ្នោតម្តងៗអ្នកសង្កេតការណ៍តែងរាយការណ៍ពីភាពរងគ្រោះរបស់សមាជិកគណបក្សប្រឆាំង នឹងនយោបាយរដ្ឋាភិបាល តើគណបក្សលោកមានជួបប្រទះព្រឹត្តិការណ៍នេះខ្លះៗហើយ ឬនៅ?

**យ៉ែម ប៉ុញ្ញារិទ្ធ :** ស្ថានភាពជាក់ស្តែង គឺសកម្មជនយើងពីររូបនៅកំពង់ចាមត្រូវគេចាប់ខ្លួន ឥឡូវត្រូវគេដោះលែងនៅក្រៅឃុំតែត្រូវទៅបង្ហាញខ្លួន នេះបញ្ជាក់ឱ្យឃើញថា ការបំភិតបំភ័យបំបាក់ស្មារតីអ្នកដែលគិតគូរពីបញ្ហាជាតិ តែងតែមាននៅមុនពេលបោះឆ្នោតម្តងៗ

**ខ្មែរប៉ុស្តិ៍ :** តើគណបក្សសិទ្ធិមនុស្សមានគិតទេថា នឹងមានសមាជិកខ្លួនប៉ុន្មានរូបនឹងចូលទៅអង្គុយអាសនៈសភាជាតិឆ្នាំ២០១៣?

**យ៉ែម ប៉ុញ្ញារិទ្ធ :** យើងមិនទាន់បានគិតដល់ឆ្នាំ២០១៣នៅឡើយទេ ព្រោះកំពុងផ្តោតការប្រឹងប្រែងលើការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ ជាអាទិភាពយើងយល់ឃើញថា យើងត្រូវការឱ្យមានសមាជិកយើងនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ជាមេឃុំក្តី ជាជំទប់ក្តីយើងនឹងរៀបចំអនុវត្តន៍គោលនយោបាយរបស់យើង និងផែនការណ៍អ្វីដែលយើងបានលើកជូនប្រជាពលរដ្ឋឱ្យបានឃើញជាក់ស្តែងជាមុនសិន។

(សូមរង់ចាំអានវគ្គទីពីរ នៃបទសម្ភាសន៍)


# ក្រុមហ៊ុនទេសចរណ៍ ភ្នំពេញអន្តរជាតិ

**Phnom Penh International Travel Services**

21 Branch St., Ste #1
Lowell, MA 01851
Tell: 978-970-5999
Fax: 978-970-5599

109 Lafayette St. #C-5
New York, NY 10001
Tell: 212-219-2299
Fax: 212-219-9930

- លក់សំបុត្រយន្តហោះសម្រាប់ក្នុង និងក្រៅប្រទេស
- ធ្វើលិខិតធានា ប្តី ប្រពន្ធ ឬគូដណ្តឹងពីស្រុកខ្មែរ
- ធ្វើលិខិតសុំច្បាប់ចេញចូល -Re-Entry Permit
- ពន្យា Passport ខ្មែរ Laisser Passer
- ធ្វើទិដ្ឋាការ Visa ទៅអាស៊ី
- ធ្វើលិខិតសុំ Green Card I-94 Work Permit
- បំពេញសុំចូលសញ្ជាតិ
- ថតរូបសម្រាប់ចូលសញ្ជាតិ និងទទួលផ្ញើប្រាក់ទៅស្រុកខ្មែរគ្រប់ប្រទេស
- លក់ Money Order និងបោះត្រា Nortary Public




978-970-5999



**KHMER POST USA, LLC**
**East Coast Publication**

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im, Audria Chea,**

*Contributed Writers:*
**Mam Yin, Kim Phien, Lanica Angpak, &**
KhmerPostLowell@gmail.com

**Soben Pin**
*Marketing Director*
KhmerPostUSA@gmail.com
**267-253-3947**
**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Mong Meng**

~~~~~~

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Pennsylvanian & Massachusett.

~~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year. Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

~~~

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



# ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្រ្ចាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment ACCEPTED ទទួលគ្រប់ អិនស៊ូរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



**FREE**
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 10/30/11

"EXCLUSIVE OFFER"
$55.00
*Limited Time New Patient Special*
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or Insurance. Expires 10/30/11

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ប៉ានិស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com
~~~

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា ស៊ីន សាន


លោក ម៉ិច យឹន

ដោយ : ម៉ិច យឹន

●●● មានភាពមហាធ្ងន់ធ្ងរខ្លាំងណាស់រកអ្វីមកប្រៀបផ្ទឹមឱ្យស្មើរុំបានឡើយ ។ តើនៅត្រង់ណាដែលថាប្រជាធិបតេយ្យនោះ? បើកាប់សម្លាប់ជាតិខ្មែរយ៉ាងរង្គាលដូច្នេះ?

ជីវិតជនជាតិខ្មែរ ស្លូតត្រង់បានត្រូវបាត់បង់ទៅគ្មានលោះម៉ោងណាសោះឡើយ មានភូមិខ្លះដែលមានបណ្តាជនត្រូវអង្គការឱ្យទៅនៅរួចគ្នា ដោយធ្វើការរួមគ្នា បរិភោគអាហាររួមគ្នាតាមកម្រិតដែលអង្គការកំណត់ឱ្យរហូតដល់ពេលខ្លះអង្គការផ្តល់ឱ្យតែបបររាវ ស្ទើរតែគ្មានគ្រាប់អង្ករចែកឱ្យបរិភោគ ចំណែកការងារនៅក្នុងស្រែចំការត្រូវអង្គការបង្ខំឱ្យធ្វើកាន់តែសស្រាកសស្រាំខ្លាំងឡើងទាំងយប់ទាំងថ្ងៃ មានបណ្តាជនតិចណាស់ដែលអាចទ្រាំទ្ររស់បានមានជីវិតបានទាំងត្រដរនៅពេលនោះ ។

មានភូមិខ្លះមានបណ្តាជនរាប់ពាន់នាក់ត្រូវបាត់បង់ជីវិតអស់រលីង ភូមិនោះបានក្លាយទៅជាភូមិថ្នូរខ្មោច ដោយហេតុជនដែលស្លាប់ត្រូវដេកស្លាប់ទាំងគ្រួៗនៅក្នុងផ្ទះនោះតែម្តង ខ្លះកប់ ខ្លះទុកចោលនៅរាត់រាយពាសពេញដីក្នុងភូមិទាំងមូល ។ ចំណែកសពខ្លះដែលយកទៅកប់ក៏កប់ពុំបានត្រឹមត្រូវបណ្តាលឱ្យសត្វចចក ស្វាទាំងហ្វូងចេញមកអូសទាញសពយកទៅស៊ីពេញវាលស្រែគ្រប់ទីកន្លែង ឃើញមានសុទ្ធតែឆ្អឹងសពសស្កុះដូចសំឡីនៅពាសពេញទាំងអស់គួរឱ្យអនិច្ចាណាស់ជីវិតដ៏អភព្វនៃជនជាតិខ្មែរស្លូតត្រង់ត្រូវអង្គការបក្សប្រជាជនបដិវត្តន៍ធ្វើឃាតគ្មានត្រាប្រណីបន្តិចបន្តួចសោះ។

សម្រែកទួញយំថ្ងូ និងសម្រែកដង្ហោយហៅឱ្យអង្គការមកបាញ់សម្លាប់ភ្លាមៗទៅ កុំទុកឱ្យរស់ក្នុងអន្លង់ទុកមហាវេទនាខ្លោចផ្សានេះយូរពេកបានបន្លឺឡើងឮពេញភូមិនីមួយៗ លាយដោយសម្រែកស្រែកសុំអាហារឱ្យបានមួយឆ្អែតមក រួចហើយបាញ់សម្លាប់ចោលទៅចុះមិនចង់រស់នៅតទៅទៀតទេ ។

ស្ថានភាពដ៏មហាសែនវេទនា សោយសោកនេះជាសោកនាដកម្មមួយមិនគួរណាឱ្យប្រជាពលរដ្ឋខ្មែរ ដែលមានជីវិតរស់នៅសព្វថ្ងៃទោះបីបានធ្លាប់រស់នៅក្រោមអំណាចគ្រប់គ្រងរបស់អង្គការបក្សប្រជាជនបដិវត្តន៍ខ្មែរ កម្ពុជាប្រជាធិបតេយ្យក្តី និងប្រជាពលរដ្ឋដែលកើតក្រោយសម័យនេះក្តីក៏ដោយមិនត្រូវនាំគ្នាបំភ្លេចរឿងនេះចោលបានទេ។

ការដែលយើងបំភ្លឺរឿង ដ៏មានអត្ថន័យខ្លឹមសារ សំរាប់ជីវិតនេះហើយដែលបណ្តាលឱ្យប្រទេស និងប្រជាជាតិ ត្រូវរលាយសាបសូន្យទៅអនាគតដ៏ខ្លីខាងមុខ ។ ពីព្រោះអ្វី?

-ពីព្រោះ ការសម្លាប់ជនជាតិសាសន៍ខ្មែរនេះ គឺជា គម្រោងផែនការនៃប្រទេសជិតខាងខ្មែរ ទាំងកុម្មុយនិស្ត ទាំងសេរី មានទាំងប្រទេសខ្លះនៅឆ្ងាយពីប្រទេសខ្មែរផងដែរ ដូចជាសំដីរបស់មេដឹកនាំខ្មែរថ្នាក់កំពូលខ្លះ ថ្នាក់បន្ទាប់ខ្លះ មានទាំងស្តេច មានទាំងមិនមែនស្តេច បាននិយាយបញ្ជាក់ប្រាប់ប្រជាពលរដ្ឋខ្មែរ និងប្រជាពលលោកឱ្យបានដឹងយ៉ាងច្បាស់ពិតប្រាកដណាស់ថា "សង្គ្រាមកាប់សម្លាប់ពលរដ្ឋខ្មែរជាម្ចាស់ស្រុក គឺជាគម្រោងផែនការនៃជនជាតិសាសន៍ដទៃ ដែលមានអ្នកដៃដល់ជាងគេ គឺបក្សប្រជាជនបដិវត្តន៍យួនយៀកណាម ដែលគេបានធ្វើឱ្យគម្រោងផែនការនេះបានសម្រេចជាស្ថាពរកាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពិតប្រាកដណាស់។

**ភាគ៥-គម្រោងផែនការយួន មកលើប្រទេសខ្មែរ**

ទោះបីមានក្រុមមួយ ដែលបែកចេញពីអង្គការបក្សប្រជាជនបដិវត្តន៍ខ្មែរ កម្ពុជាប្រជាធិបតេយ្យបានទៅសុំអង្វរកងទ័ពយួនក្រហមឱ្យមកវាយលុកលុយប្រទេសខ្មែរបានអះអាងថា មកវាយលុកដើម្បីកំចាត់ពួកកម្ពុជាប្រជាធិបតេយ្យ ហើយរំដោះជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរឱ្យបានរួចពីការកាប់សម្លាប់របស់កម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏មតិជនជាតិខ្មែរ និងអ្នកមានវិចារណញាណបានតាមដានព្រឹត្តិការណ៍ផ្សេងៗ ដែលកើតមាននៅលើជនជាតិខ្មែរ និងប្រទេសខ្មែរតាំងពីសម័យមុនប្រទេសបារាំងចូលមកត្រួតត្រាឥណ្ឌូចិនតមកដល់សង្គ្រាមឥណ្ឌូចិន ដើម្បីទាមទារឯករាជ្យពីប្រទេសបារាំង រហូតមកដល់ប្រទេសទាំង៣ ខ្មែរ លាវ យួន បានឯករាជ្យក្នុងឆ្នាំ ១៩៥៣-៥៤។



ជាពិសេសមានឯកសារមួយចំនួន ត្រូវបានរកឃើញថា ប្រទេសយួន និងរដ្ឋាភិបាលជាកុម្មុយនិស្តក្តី ជាសេរីក្តី សុទ្ធតែមានគម្រោងផែនការយ៉ាងល្អិតល្អន់ និងខ្ជាប់ខ្ជួនថា ត្រូវតែខិតខំប្រឹងប្រែងធ្វើឱ្យផែនការពង្រីកទឹកដីរបស់យួនត្រូវតែឱ្យបានសម្រេចជាស្ថាពរ ។ តទៅលេខក្រោយ







# Lowell: Restaurant &Bar for Sale

## ដំណឹងលក់ហាងជាបន្ទាន់

Full Liquor License មានឡៃស៊ិនបា

QUICK SALE!!!! ត្រូវលក់ជាបន្ទាន់ម្ចាស់ត្រូវរើទៅរដ្ឋផ្សេង

More Information contact Mr. Huong – **978-289-7878**

សូមទាក់ទងលោក ហ៊ឹង តាមទូរស័ព្ទ **978-289-7878**









SOUPER BOWL RESTAURANT
1733 Middlesex Street Lowell, MA 01851 978.937.3388
www.facebook.com/souperbowlrestaurant

# ការិយាល័យវេជ្ជបណ្ឌិត

## ខេវិន : (267) 210 8880



ក្រុមហ៊ុនយើងមានបទពិសោធន៍ ១០ឆ្នាំក្នុងការព្យាបាល :

| | |
|---|---|
| Slip & Fall | រអិល និងដួល |
| Auto Accident | គ្រោះថ្នាក់រថយន្ត |
| Back Pain | ឈឺខ្នង |
| Headache | ឈឺក្បាល |
| Neck Pain | ឈឺកញ្ចឹងក |



- មានអ្នកបកប្រែ និយាយភាសាខ្មែរ, ខេវិន TeL: (267) 210 8880
- មានការណែនាំជូន មេធាវី ដែលមានបទពិសោធន៍ច្រើនឆ្នាំ

**South Office:** 215-776-6215
PAIN & INJURY
CHIROPRACTIC CENTER
1100 Washington Ave., Lot C, Unit #C2
Philadelphia, PA 19147
Tel. 215-468-7256

**North Office:** 267-408-6150
VN Chiropractic Center
5416 N. 5th St.
Philadelphia, PA 19120
Tel. 215-324-1400

# ទីកន្លែងល្អសម្រាប់បើក ភោជនីយដ្ឋានខ្មែរ ចិន ឬវៀតណាម!








-នៅជាប់គ្នានឹងហាងកូរ៉េដែលល្បីឈ្មោះធ្វើពីផ្សារហុងកុងតែ៥នាទីទេ និងមកតីនេះ ហើយទីនេះសំបូរទៅដោយជនជាតិ ចិន វៀតណាម និងខ្មែររស់នៅ។
-មានកន្លែងចតរថយន្តបាន ៧៥ ហើយមានអាជ្ញាប័ណ្ណសម្រាប់បើកភោជនីយដ្ឋានរួចជាស្រេច កន្លែងនោះពីមុនជាហាងគុយទាវទំហំ២,៥០០ស្កែហ្វីត

**JUST NEXT TO FAMOUS KOEREAN RESTAURANT**
**75 CARS PARKING LOT**
**HERE ARE ALREADY RESTAURANT PERMIT AND ZONING**
**IT WAS FORMERLY NOODLE HOUSE**
**2,500 SQUARE FEETS**

*Mr Peter Han* **215.668-1666**



# Yoo's Auto Service and Collision

## យូ បំរើសេវារថយន្ត

### នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច



**FREE ESTIMATES**

យើងអាចជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

**ផ្នែកជាងម៉ាស៊ីន**

Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

**ផ្នែកជួសជុលតួរថយន្ត**

Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists




**189 W. Duncannon Ave. Phila., PA 19120**

**ទូរស័ព្ទលេខ SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475**

---

# ឱសថស្ថានខ្មែរ

BUY RITE 267-297-5879

**ឱសថការីខ្មែរ ជែន ចាច់** នៅ Old York Rd និង Rockland St




- ផ្ញើថ្នាំជូនដល់ផ្ទះដោយឥតគិតថ្លៃ
- ទទួលអ៊ិនសួរិនស្ទើរគ្រប់មុខ
- ទទួលបន្តផ្តល់ថ្នាំដែលលោកអ្នកកំពុងប្រើទិញមកពីឱសថស្ថានផ្សេងៗ
- តម្លៃថោកៗបំផុត និងមានស្តុកឱសថគ្រប់មុខប្រភេទ
- ផ្តល់សេវាដោយរហ័សទាន់ចិត្ត
- មានឱសថវីតាមីន-ឱសថចិនសែ និងឧបករណ៍ព្យាបាលមុខជំងឺ

**ម៉ោងធ្វើការ :**
ចន្ទ-សុក្រ : 9am-7pm
សៅរ៍ : 9am-5pm
អាទិត្យ : បិទទ្វារ

**1337 W. Rockland St.**
**Philadelphia, PA 19141**
**Tel: 267-297-5879**
**Fax: 267-297-5880**

**បំណ្ណរង្វាន់ $30**

សំរាប់ភ្ញៀវដែលមានអាយុពី៦៥ឡើងទៅបើផ្ទេរបញ្ជាទិញថ្នាំពីរ ឬលើស យើងនឹងជូនបំណ្ណរង្វាន់៣០ដុល្លារ សំរាប់អ្នកមាន Insurance បំណ្ណរង្វាន់មួយសំរាប់ភ្ញៀវ១នាក់ មិនអាចផ្ទេរឱ្យអ្នកដទៃ ផ្តល់រង្វាន់នេះ ក្នុងរយៈពេលខ្លី ហើយយើងខ្ញុំមានសិទ្ធិនឹងបញ្ឈប់ដោយមិនចាំបាច់ប្រាប់មុន

Free $30 Gift Card
with two or more new or transferred prescriptions.
Limit one per customer. non-transferable, for Limited time only. Buy Rite has the right to cancel the promotion at any time without notice. Disclaimer: This discount is not insurance. Offer not valid with prescriptions covered by medicaid, Medicare, or any other governmental pay programs or where prohibited by law.

---




សូមអញ្ជើញមកលំហែរអារម្មណ៍ កំដាត់ភាពអាប់អួរ!

# ភោសជ្ជៈដ្ឋាន ហ្វៀ

*Bar's Open*
*Monday-Saturday*
*10a.m.–2a.m.*
*Sunday*
*11a.m.–2a.m.*

**198 W. Godfrey Avenue.**
**(Corner of Godfrey & 2nd St.)**



Philadelphia, PA 19120
**215-621-7563**

---

# Vihi insurance-Income Tax Mortgage-Realty

**ធានារ៉ាប់រង_តាក់លើប្រាក់ចំណូល_ខ្ចីប្រាក់ទិញផ្ទះ_ទិញលក់ផ្ទះ**

**Insurance** **ធានារ៉ាប់រង**
(Licensed PA, NJ & DE) អាជ្ញាប័ណ្ណ PA, NJ & DE
Home • ផ្ទះ Car • រថយន្ត
Business • មុខរបរ Health • សុខភាព

**Income Tax** **តាក់លើប្រាក់ចំណូល**
Individual • ផ្ទាល់ខ្លួន Business • ពីមុខរបរ
Pay Roll • ពីប្រាក់ខែ
Forming New Business • បង្កើតមុខជំនួញថ្មី
Home Deed Transfer • ប្តូរឈ្មោះផ្ទះ
Auto Title Transfer • ប្តូរឈ្មោះម្ចាស់រថយន្ត




**Vihi Mortgage Vihi ខ្ចីប្រាក់ទិញផ្ទះ**
(Licensed by PA Dept. of Banking) • អាជ្ញាប័ណ្ណពី PA ការិយាល័យធានាគារ
Hiep Vo, MBA, President. • ហៀប វ៉ូ MBA ប្រធាន
Finance/Refinance your home • ផ្តល់ប្រាក់កម្ចីក្នុងការទិញផ្ទះទិញដំបូង ឬកណ្តាលទី
Low interest Rate & Down Payment • ការប្រាក់ថោក និងលុយកក់តិច
Fast Preapproval • ចម្លើយលឿន

**Vihi Realty Co**
Dr. Hanh Vo, Broker/Owner Cell (267) 664-2689
Buy & Sell Properties & Businesses
Visit: www.drhanh.net for more foreclosure homes

**North Phila – 215-276-8441**
**5225 N. 5th Street**
**Phila., Pa 19120**

**South Phila – 215-336-0600**
**1519 W. Passyunk Ave.**
**Phila., Pa 19145**
**www.vihifinancial.com**

# ហាងមាសខ្មែរអង្គរ

**Khmer-Angkor Jewelry**

金美成珠寶行

Since 1983
Certified Diamonds & Diamond Jewelry

600 Washington Avenue. Unit 12B. Philadelphia, PA 19147
Tel. 215-599-2222 Fax. 215-599-2223



18K & 24K Gold, Platinum Jewelry & Watches
GIA Graduate Gemologist on Staff
Authorized RADO & LONGINES Dealer
Repairs Done on Premises

Open
Tuesday-Sunday
10:30AM-6:30PM
Closed Monday

# ហាងមាសរស្មី

**SUNSHINE JEWELRY, INC.**

215-271-2950



Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong



702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com

# Phở Hà Saigon

Vietnamese Restaurant

7 days A Week
9am-9pm

B.Y.O.B.



ជាហាងដែលធ្វើ ហ្វើ ឆ្ងាញ់ជាងគេនៅហ្វីឡាដែលហ្វៀ
ចុងភៅដែលពូកែធ្វើ ហ្វើ និងម្ហូបផ្សេងៗឯទៀត
ត្រូវមាត់ភ្ញៀវគ្រប់ៗរូប ឥឡូវនេះមកធ្វើម្ហូបនៅហាងយើងខ្ញុំ
ហើយធានាថា ម្ហូបអាហារហាង Phở Hà Saigon
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា




320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)

VISA MasterCard DISCOVER

# NEW CHINA PEARL

DIM SUM & DINNER EVERYDAY

288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell 93 South; Exist 37B, from RT-128; Exit 36.



ភោជនីយដ្ឋាន "ញូឆាណាភើល" សូមអញ្ជើញលោកអ្នក និងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាជុំវិញ ។ យើងមានសាលរាំកំសាន្តសំរាប់ពិធីការ ឬរាត្រីជួបជុំគ្នាមានបា និងខារ៉ាអូខេទៀតផង កន្លែងចតឡានមិនយកថ្លៃហើយមាន

Ballrooms for Wedding & Party
មានឆាករាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត

ZAGAT RATED — Very Good to Excellence Food. Boston Restaurants. 2011/2012"

**LIVE FRESH SEAFOOD**
-SPECIAL LIMITED OF TIME $20.00 TWIN LOBSTER
-SAME AS CHINA TOWN FOOD AND CHIEFS.

BUSINESS HOURS: Mon – Wed 11 a.m. – 10 a.m./Thurs. & Fri. 11 a.m. - 12 a.m
Sat. 10 a.m. - 12 a.m / Sun.10 a.m. – 10 p.m.
Delivery Hours 11 a.m. – 9 p.m. min. $15 order plus $2 delivery.






# ភោជនីយដ្ឋាន ឆាយណាស្តារ China Star

អាហារចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកង់តុង
ម្ហូបម៉ង់ដារីន

Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507

Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM



យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to 1:00 AM Available to most areas. Min. $10.00 Delivery Charge $2

$16.95

បង្កងឆាខ្ញីម និងខ្ទឹមពិសេស
SPECIAL 2 Lobsters w/ Scallion & Ginger



# Massachusetts Council on Compulsive Gambling

*We understand the problem. We can help.*

## ក្រុមប្រឹក្សារដ្ឋម៉ាសាឈូសេតសំរាប់ការញៀនល្បែងស៊ីសង

"ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ មានបញ្ហាញៀនល្បែងស៊ីសង សូមទូរស័ព្ទមកលេខខាងក្រោម អាចជួយជាអ្នកសម្ងាត់ ហើយសួររកសៀវភៅសម្រាប់ឱ្យអាចជួយខ្លួនឯងបានជាភាសាខ្មែរដោយឥតគិតថ្លៃ"

# 1-857-383-3577

ជំហានដំបូងរបស់អ្នកឆ្ពោះទៅកាន់ការផ្លាស់ប្ដូរ

www.asianproblemgambling.org




10th Anniversary
Philadelphia International
Dragon Boat Festival
Saturday
October 1, 2011
អាល់ប៊ុមរូបថតប្រចាំសប្តាហ៍


ភ្ជុំបិណ្ឌនៅវត្តបាលីល័យ


ភ្ជុំបិណ្ឌនៅវត្តព្រះពុទ្ធប្រទានពរ


ភ្ជុំបិណ្ឌនៅវត្តសុរិយារង្សី

តមកពីទំព័រទី ១

# ភាពយន្តឯកសារ“នណាសម្លាប់...

បានជីកកកាយតាមរយៈភាពយន្តមានរយៈពេលជិតមួយម៉ោង ដែលសាច់រឿងបង្ហាញពីភាពអយុត្តិធមិក្នុងសង្គមកម្ពុជានាបច្ចុប្បន្នជាពិសេសបង្ហាញឱ្យឃើញពីនិទោនភាពរបស់ប្រព័ន្ធតុលាការកម្ពុជាក៏ដូចជាការឱ្យតម្លៃដល់អាយុជីវិតនៃពលរដ្ឋខ្មែរទាបជាងសត្វតិរិច្ឆានពីសំណាក់ក្រុមអ្នកមានអំណាចព្រមទាំងរឿងរ៉ាវមិនប្រក្រតីមួយចំនួនទៀត ដែលកំពុងស៊ីរូងក្នុងសង្គមកម្ពុជា។

តាមរយៈឯកសារនោះបានបង្ហាញថា លោក ជា វិជ្ជា គឺជាតួអង្គមួយដ៏សំខាន់ក្នុងសាច់រឿង ដែលបានចេញមុខក្នុងការធ្វើបាតុកម្ម, កូដកម្មប្រឆាំងនឹងរោងចក្រសហគ្រាសមួយចំនួនក្នុងប្រទេសកម្ពុជាដើម្បីឱ្យភាគីក្រុមហ៊ុនគោរពន្ធូវលក្ខខ័ណ្ឌការងារ, តម្លើងប្រាក់ខែគោលរបស់កម្មករ ។ល។ ហេតុដូច្នេះហើយ ទើបប្រធានសហជីពសេរីមួយនេះបានក្លាយជាបន្លានៅក្នុងកែវភ្នែករបស់ក្រុមហ៊ុនកាត់ដេរបរទេសមួយចំនួន និងក៏ជាឆ្អឹងទទឹងករបស់រដ្ឋាភិបាលកម្ពុជាផងដែរ ។ ដូច្នេះ ដើម្បីដកបន្លាដ៏មុតស្រួចចេញពីកែវភ្នែក និងយកឆ្អឹងចេញពីបំពង់កចេញនោះ តើគេត្រូវធ្វើយ៉ាងដូចម្តេច? ពុំចាំបាច់ឆ្ងល់ឡើយ គឺត្រូវ "ផ្តាច់ជីវិត" ។ ទាំងអស់នេះ គឺជាអាថិកំបាំងដែលត្រូវជីកកកាយនៅក្នុងភាពយន្តឯកសារ ។ ក៏ប៉ុន្តែមុននឹងខ្មាន់កាំភ្លើងដៃឆើតបាញ់សម្លាប់លោក ជា វិជ្ជា លោកក៏ត្រូវបានដឹងខ្លួនជាមុនដែរថា នឹងមានការប៉ុនប៉ងសម្លាប់ដូចជាកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៣ ត្រូវបានជនអាមេរិក ដែលគេសង្ស័យថា ជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលបានផ្ញើរសារជាភាសាអង់គ្លេសចូលមកកាន់ទូរស័ព្ទលោក ជា វិជ្ជា ថា "A dog I will kill you " ដែលមានន័យជាភាសាខ្មែរថា "អាឆ្កែ អញនឹងសម្លាប់ឯង"។ នឹងនៅពេលក្រោយ១មកទៀត ក៏មានមន្ត្រីប៉ូលីសបានប្រាប់លោក ជា វិជ្ជា ឱ្យគេចខ្លួនចេញពីប្រទេសខ្មែរជាបន្ទាន់. បើពុំដូច្នោះទេ គេនឹងសម្លាប់ ប៉ុន្តែលោក ជា វិជ្ជា នៅតែមានៈពុំព្រមចាកចេញពីប្រទេសកម្ពុជាឡើយ តែផ្ទុយទៅវិញ លោកនៅតែប្រឈមទៅនឹងល្បែងគ្រោះថ្នាក់នេះដដែល ។ "ខ្ញុំមិនខ្លាចទេ បើខ្ញុំខ្លាចមានន័យថាដូចខ្ញុំស្លាប់អញ្ចឹង..." នេះជាសំដីលោក ជា វិជ្ជា ថ្លែងទៅកាន់អ្នកស៊ើបអង្កេតផ្នែកសិទ្ធិមនុស្ស។


ពុទ្ធបរិស័ទកំពុងមើលកុននរណាសម្លាប់ជីវិជ្ជា( ថតរូបដោយ វិសាល រស់)

នាព្រលឹមអរុណរះណោទ័យ ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ដែលជាទេសកាលបុណ្យចូលឆ្នាំចិន គឺជាថ្ងៃអវសាន្តនៃប្រធានសហជីពសេរី ដែលត្រូវបានគេផ្តល់រហស្សនាមថាជា "វិរៈបុរសរបស់កម្មករ,កម្មការនី" ។ គ្រាប់កាំភ្លើងចំនួន២គ្រាប់ត្រូវបានទម្លាយក្បាល និងដើមទ្រូងផ្នែកខាងឆ្វេងរបស់លោក ជា វិជ្ជា ឱ្យដេកដួលក្រាល ដោយព្រំលោហិតក្រហមឆ្អៅគួរឱ្យរន្ធត់ទាំងព្រឹកព្រលឹមក្នុងខណៈដែលលោកកំពុងអានកាសែត ។ ភ្លាមនោះឃាតករពិតប្រាកដត្រូវបានសាក្សីម្នាក់ដែលជាម្ចាស់តូបកាសែតគឺអ្នកស្រី វ៉ា សុធី អះអាងថា មានចំនួន២រូប ដោយម្នាក់ជាខ្មាន់កាំភ្លើង និងតួរកនម្នាក់ទៀតជាអ្នកឌុប ។

ទោះជាយ៉ាងនេះក្តី ការស្លាប់របស់លោក ជា វិជ្ជា ក៏នៅពុំទាន់ចប់ត្រឹមហ្នឹងឡើយ ហើយចំពោះអ្វីដែលជាក្តីកង្វល់ និងជាឧបសគ្គរបស់រដ្ឋាភិបាលកម្ពុជានោះ គឺម្ចាស់ជំនួយអន្តរជាតិទាមទារឱ្យមានការចាប់ខ្លួនឃាតករជាបន្ទាន់ ដើម្បីយកមកកាត់ទោសតាមផ្លូវច្បាប់ ។ មកដល់ចំណុចដ៏រសើបនេះយើងសូមដាក់ជាកូនសំណួរមួយថា "តើឃាតករពិតប្រាកដនៅឯណា ហើយនរណាជាអ្នកបញ្ជាឱ្យសម្លាប់?"។ ទាំងអស់នេះ គឺជាសំណួរដែលនៅពុំទាន់មានចម្លើយពិតប្រាកដរហូតមកដល់បច្ចុប្បន្ននេះ ប៉ុន្តែបើយោងតាមប្រសាសន៍របស់លោក ជា មុនី ប្អូនប្រុសបង្កើតរបស់លោក ជា វិជ្ជា ធ្លាប់បានអះអាងថា "រដ្ឋាភិបាលជាអ្នកសម្លាប់លោក ជា វិជ្ជា"។

ទោះបីនរណាជាឃាតករពិត ឬមិនពិតក្តី គឺគ្មានសំខាន់ឡើយ តែប្រការដែលសំខាន់នោះ គឺត្រូវតែចាប់មនុស្សពីរនាក់ ដើម្បីប្រាប់ដល់ម្ចាស់ជំនួយអន្តរជាតិថា "ឃើញទេ ឃាតករពិតជារត់ទៅណាមិនឆ្ងាយពីក្បៀកសមត្ថកិច្ចឡើយ"។ រំលង៥ថ្ងៃនៃមរណៈដ៏សោកសង្រេគលោក ជា វិជ្ជា ប៉ូលីសបានបង្ហាញនូវរូបគំនូរព្រៀងមនុស្សប្រុសម្នាក់ ដែលជាមុខសញ្ញាត្រូវចាប់ខ្លួន ។ តទៅទំព័រទី ២២


# ក្រុមហ៊ុនធានារ៉ាប់រងដែលបានបំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

# East Coast Center

## for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមានអាការៈដូចជាៈ ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

# Cambodian National Conference



*Commemorating the 20th Anniversary of the Paris Peace Agreement*

## "Cambodia 20 Years after the Paris Peace Agreement"

*Friday & Saturday October 21-22, 2011*

*Speakers from: Cambodia, France, U.S. government, Sam Rainsy Party, Human Rights Party and more.*

*Washington, DC Metropolitan Area*

*Holiday Inn, 2460 Eisenhower Ave, Alexandria, VA 22314 ph. (703) 960-3400*

**Admission Fee: $100/person or $50/Student**

Includes: Friday's refreshments & cocktails and Saturday's breakfast, lunch and dinner

Please join us for this important event RSVP by Friday, October 14, 2011

For more info, visit or contact: www.CAHRAD.org or www.khmerunity.org | Email: cnc2011@CAHRAD.org

Chhang Marith (360) 636-3989 | Mong Heng (703) 256-3295 | Sinoun Hem (253) 228-5173
Hay San Meas (253) 381-8291 | Montha Ok (703) 447-0644 | Tithia Sum (360) 438-9034
John Yuth (703) 967-9919 | Nicole Ung (561) 386-0634 | Tung Yap (703) 675-3997
Kao Our (215) 782-3429 | Rany Lushinski (703) 723-4273 | Van Sar (425) 672-6725
Kim Hort Ou (215) 483-0160 | Saunora Prom (703) 802-4750 | Vibol Tan (703) 496-4636
Marie Chea (703) 327-4104 | Sieu Meas (253) 381-8511

Organized by Cambodian Americans for Human Rights and Democracy (CAHRAD) and Khmer Unity for Cambodia (KUC)



# ANGKOR AUTO SERVICE, INC.

## ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

**Auto Body and Maintenance**



BODY WORKS

Auto glass and windshields

Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស៊ូរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



# BX Towing LLC

## "បេអិច" អូសរថយន្ត២៤ម៉ោង

**215-989-1585**

**Bob**

Fast & Affordale
24Hrs. Services



600 Washington ave., Ste.8
Philadelphia, PA 19147

Fax : 267-371-5177
botwingllc@gmail.com





# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



# Nationwide

*Insurance & Financial Service*

## ក្រុមហ៊ុនធានារ៉ាប់រង និងហិរញ្ញវត្ថុ



*Life* *Home* *Health* *Auto* *Bussiness*

- ធានារ៉ាប់រងជំនួញលោកអ្នក
- ធានារ៉ាប់រងផ្ទះសម្បែង
- ធានារ៉ាប់រងសុខភាព
- ធានារ៉ាប់រងរថយន្ត
- ធានារ៉ាប់រងជីវិត

ចុះតម្លៃ ៣០% បន្ថែម បើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

# អាថ៌កំបាំង និងសិល្បៈនៃជីវិត

# SECRET AND ART OF LIVING



(តមកពីលេខមុន)

**រៀបរៀងដោយ**
**លោក ម៉ៅ ច័ន្ទសំណុំ**

--ឃុំគ្រងយើងជាយូរមកហើយ ។ ការហាត់ស្តាប់សម្លេងក្នុងក្បាលនេះមានន័យថា សតិយើងលែងឈរឋិតនៅក្នុងចរន្តគំនិតទៀតហើយ សតិនៅក្រៅចរន្តហើយបាញ់ភ្នែកទៅមើលវា ។ បន្តិចម្តងៗអ្នកនឹងពិសោធឃើញមានលំហ Space លេចឡើងជាស្វ័យប្រវត្តិនេះ មានន័យថា ចរន្តគំនិតត្រូវបានផ្តាច់ Disconnection of the thought flow or the gap of thoughts ។ បើបន្តស្តាប់ទៅទៀត អ្នកនឹងទទួលអារម្មណ៍ស្ងប់ peace ភាពស្រណុកស្រួល Ease of mind ភាពសប្បាយរីករាយពីក្នុងលេចពន្លឺមក Joyful mind ។ ហើយបើអ្នកត្រូវការគិតគូរតទៅទៀត សូមបាញ់សតិត្រឡប់ទៅក្រៅវិញ ។ ម្តងនេះខួរក្បាលយើងថ្មី Fresh mind គំនិតថ្មីៗមានឱកាសជ្រៀតចូលមកបានព្រោះកន្លងមកមានលំហ ។

យើងអាចអនុវត្តរបៀបនេះដោយប្រើរយៈពេលខ្លីកន្លះនាទី មួយនាទីឡើងទៅតាមកាលៈទេសៈកំណត់ ។ ចំណុចមួយទៀតសំខាន់ដែលគួរកត់សំគាល់គឺ សតិអាចបង្វិលទៅក្នុង ឬទៅក្រៅភ្លឹបភ្លែតៗ ។ របៀបនេះ បើកផ្លូវអនុញ្ញាតឱ្យយើងម្នាក់ៗរស់នៅក្នុងពិភពទាំងពីរនេះគឺ ពិភពក្នុងលំហូរគំនិត និងក្រៅលំហូរគំនិត (ឬក្រៅម៉េម៉ូរី) ។

ជាធម្មតា គំនិតហូរចេញពីម៉េម៉ូរីមកបន្ទាប់មកប្រតិកម្ម ហើយកើតមានលេចរូបរាងជាការរំជួលចិត្ត មនោសញ្ចេតនា Emotions ។ ដំណើរម៉េម៉ូរី លំហូរគំនិត ប្រតិកម្ម ការរំជួលចិត្តប្រព្រឹត្តទៅជាខ្សែចង្វាក់ហូរហែរតៗគ្នាពុំដាច់ ។ ដូចខ្ញុំជំរាបខាងលើស្រាប់ នៅពេលយើងអនុវត្តការពិនិត្យលំហូរគំនិតនេះលំហមួយលេចឡើងមានន័យ ថាលំហូរគំនិតត្រូវដាច់មួយរយៈដូច្នេះខ្សែសង្វាក់ ( លំហូរគំនិត ប្រតិកម្ម ការរំជួលចិត្ត ) ត្រូវដាច់ផងដែរ ប្រតិកមក៏ត្រូវបញ្ឈប់ ការរំជួលចិត្តក៏រលាយបាត់ផងដែរ ។ ដូច្នេះហើយបានជាអារម្មណ៍ស្ងប់និងសុខស្រួលមួយគ្រា ។ បើយើងឧស្សាហ៍អនុវត្តញឹកញាប់ទៅទម្លាប់ថ្មីក្នុងខ្លួននឹងរីកដុះដាល ហើយយន្តការនេះនឹងដើរដោយស្វ័យប្រវត្តិទម្រង់នៃជីវិតថ្មីបានចាប់បដិសន្ធិហើយ ។

(ខ) ការពិនិត្យវេទនាលើរូបកាយ ដោយផ្នែកៗ ឬទាំងមូលៈ

សូមមេត្តាស្តាប់ការសន្ទនា រវាងគ្រូនិងសិស្ស ដូចខាងក្រោមនេះ:

**សិស្ស :** ឱតើធ្វើដូចម្តេចឱ្យអាចតាំងសតិក្នុងពេលបច្ចុប្បន្នបាន ? មើលនេះនែ៎ ខ្ញុំឋិតនៅចំពោះមុខលោកគ្រូទេតើ ? ខ្ញុំប្រាកដជាឋិតនៅក្នុងពលបច្ចុប្បន្នហើយ ។ ឱ

**គ្រូ :** តើមានរបស់អ្វីនៅជិតខ្លួនអ្នក ?

**សិស្ស :** អ៊ូ៎ បាទខ្ញុំឃើញពន្លឺភ្លើងចាំងភ្នែក ។ ខ្ញុំឮសម្លេងនាឡិការ តុកតាក់ តុកតាក់ៗ ។ តើរបៀបនេះហើយឬជាឥរិយាបថបច្ចុប្បន្ន តើធ្វើរបៀបនេះត្រឹមត្រូវហើយឬនៅ ?

**គ្រូ :** ត្រូវមួយកំរិតហើយ តើមានរបស់អ្វីឋិតនៅជិតអ្នកជាងនេះ ទៅទៀតឬទេ ?

**សិស្ស :** ខ្ញុំនឹកពុំឃើញទេ លោកគ្រូ ។

**គ្រូ :** របស់ដែលឋិតនៅជិតអ្នកជាងគេបំផុតគឺវេទនាលើរូបកាយនេះឯង ។ ចូរអ្នកទទួលដឹងវេទនាទាំងឡាយដែលកំពុងកើតមានពេលនេះ ។ តើអ្នកទទួលដឹងអ្វីខ្លះ ? ចូលរៀបរាប់ប្រាប់ខ្ញុំមកមើល ។

**សិស្ស :** បាទខ្ញុំក្ករពោះ រមាស់ជង្គង់ ស្រៀវឆ្អឹងខ្នង តឹងស្មា ចលនាទ្រូងលោតតាមដង្ហើម ជីបចរលោតទីបៗ ។ល។

**គ្រូ :** ល្អហើយ នេះហើយជារបៀបទៅរកបច្ចុប្បន្នសតិ ។ តើក្នុងខ្លួនមានអារម្មណ៍ដូចម្តេច បន្ទាប់មក ?

**សិស្ស :** (ស្ងៀមស្ងាត់មួយភ្លែត ) បាទទទួលអារម្មណ៍ស្ងប់និងស្រួលក្នុងខ្លួន ជាងមុននេះបន្តិច ។

**គ្រូ :** នេះជារបៀបសាមញ្ញ នៅពេលអ្នកចង់ចេញពីបន្ទប់គិត (ឥទ្ធិពលម៉េម៉ូរី Conditioning ) ភាពរំជួលចិត្តឬអារម្មណ៍ស្មុកស្មាញនានា ។ អ្នកនឹងទទួលភាពសំរួលទាំងកាយ,ចិត្តក្នុងខ្លួនភ្លាមៗ relax mind and body instantly ដោយគ្រាន់តែផ្តោតសតិទៅលើវេទនាលើរូបកាយ (សូមគ្រាន់តែមើលកុំពិចារណាឱ្យសោះ) ។ អ្នកអាចបំបែករកឃើញរបៀបផ្សេងៗទៀតដោយខ្លួនឯងដូចជា : ពេលឡើងជណ្តើរ អ្នកធ្វើយឺតៗសូមឱ្យដឹងចលនាជើងលើកដាក់ចុះប៉ះឥដ្ឋ ។ ពេលលាងដៃឮស្នូរទឹកធរៗ ទឹកក្តៅ ឬត្រជាក់ក្លិនសាប៊ូ ចូរផ្តោតអារម្មណ៍ទាំងស្រុងទៅលើវេទនារូបកាយទាំងឡាយដែលកំពុងផុះឡើងនៅពេលលាងដៃនេះ ។ ពេលបើកទ្វារចូលឡាន ចូរអង្គុយ ហើយសម្ងំបន្តិចដឹងដង្ហើមចេញចូល សំរូតសតិ ពីក្បាលដល់ចុងជើង ពីជើងឡើងមកក្បាលរហ័ស រឹតចុះរឹតឡើង ដឹងរាល់វេទនាទាំងអស់ ដែលផុះឡើងនៅពេលនោះ Moment by moment ។ ពេលចាំភ្លើងក្រហម អ្នកឆ្លៀតសំរាកសំរួលខ្លួនតាមរបៀបដឹងដង្ហើមចេញចូល ប្រមូលអារម្មណ៍ដឹងពីក្នុងខ្លួនមក នូវរាល់វេទនាទាំងឡាយកំពុងផុះឡើង Feel your body sensations from within ។ ចូរអ្នកទម្លាប់ ប្រតិបត្តិរបៀបនេះមួយភ្លែតៗ កន្លះនាទី មួយនាទី ឬពីរនាទី ។ តាមរបៀបនេះ អ្នករស់នៅក្នុងម៉េម៉ូរីផង ( គិតគូរធ្វើការងារធម្មតា) និងក្រៅម៉េម៉ូរីផង (សតិនៅនឹងវេទនារូបកាយ = សំរួល និងសំរាក) Your attention will switch on and off from your conditioning mind, feel relaxed and fresh in your brain ។ មុនដំបូងអ្នកខិតខំប្រតិបត្តិយូរៗទៅវានឹងប្រែទៅជាទម្លាប់ ហើយវានឹងមានដំណើរការជាស្វ័យប្រវត្តិ ។ ទំរង់ជីវិតថ្មីកើតមានដល់អ្នកតរៀងរហូតទៅ ។ (នេះជាតិចនិករបស់មនុស្សទំនើបសម័យឌីហ្សីតុល ប្រើប្រាស់សំរាប់សំរាកពីការងាររវល់ Meditation in 5 minutes ) ។ សូមគ្រង់យកវិជ្ជានេះដាក់ខ្លួន ជាប្រយោជន៍ទៅអនាគត ។

(គ) ការពិនិត្យការរំជួលចិត្ត នឹងប្រតិកម្ម Watching the **មានតនៅលេខក្រោយ**


# ការិយាល័យច្បាប់

## ERIK B.JENSEN P.C

*A Profesional Corporation*



**We Handle All INJURY CASES**

- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

**Criminal Defense—DUI**
Adult & Juvenile
Felonies / Misdemeanors / Drug Offenses
Weapons Charges / Murder / Manslaughter
Robbery / Burglary / Theft / Rape / Child Abuse
Drunk Driving / Traffic Violations

**BANKRUPTCY**
Sheriff Sales / Foreclosures / Repossessions
Credit Repairs / Tax Liens

**FAMILY**
Divorce / Support
Alimony / Child Custody
Protection From Abuse
Visitation / Adoptions

**BUSINESS**
Contracts / Negotiations
Litigation
Start-ups / Financing
Collections

**REAL ESTATE**
Commercial — Residential
Buying / Selling
Settlements / Closings

**TAX PROBLEM**
IRS Disputes / Tax Fraud
Audits / Liens / Levies
Tax & Estate Planning

Wills, Estates & Trusts Social Security

មានអ្នកបកប្រែភាសាខ្មែរ

Rely On Over
26 Years Of Experience



WWW.ERIKJENSENLAW.COM

we have Khmer staff



Voun Lay, BS
Marketing Coordinator
267-738-7006

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law

215-546-4700 24 HOUR AVAILABILITY 800-522-6606
1528 Walnut St., Suite 1401 Philadelphia

តមកពីទំព័រទី១៧

# ភាពយន្តឯកសារ "នរណាសម្លាប់...

មកដល់ថ្ងៃទី២៨ ខែកុម្ភៈ ឬមានន័យថា បន្ទាប់ពី៤៨ ម៉ោងនៃការបង្ហាញរូបគំនូរដល់អ្នកសារព័ត៌មានរួច មកបុរសម្នាក់ត្រូវបានចាប់ខ្លួន ដោយនោះគឺ ប៊ិន សំណាង ហើយក្រោយ មកទៀត សុខ សំអឿន ក៏ត្រូវបានចាប់ខ្លួនតាមក្រោយ។ ភ្លាមនោះ ឧត្តមសេនីយ សុន សៀងលី ស្នងការប៉ូលីសក្រុងភ្នំពេញបានធ្វើសន្និសិតកាសែតមួយប្រាប់ដល់អ្នកយកព័ត៌មានអំពីជោគជ័យរបស់សមត្ថកិច្ចក្នុងការប្រម៉ាញ់ឃាតករទៅលើប្រធានសហជីពសេរី ។





ចំពោះថ្វីដៃដ៏ល្អឯកក្នុងការប្រម៉ាញ់ឃាតករសិប្បនិម្មិតទាំងពីររូបនោះ គឺគ្មាននរណាក្រៅពី លោក ហ៊ុន សុង និងលោក លី រ៉ាស៊ី ឡើយ ដោយអ្នកទាំងពីរស្ថិតនៅក្រោមបញ្ជារបស់លោក ហេង ពៅ រីឯ ហេង ពៅ ត្រូវបានទទួលបញ្ជាពីខ្មោចលោកមេប៉ូលីស ហុក ឡង់ឌី។

តើ សុខ សំអឿន និង ប៊ិន សំណាង ពិតជាឃាតករមែនឬទេ? ហើយនៅថ្ងៃកើតហេតុអ្នកទាំងពីរនៅឯណា? ។ តាមរយៈនៃខ្លឹមសារឯកសារភាពយន្ត "នរណាសម្លាប់ ជា វិជ្ជា" របស់លោក Bradley Cox បានស្តែងឱ្យឃើញនូវភស្តុតាងសម្បូរបែបស្តីពី សុខ សំអឿន និង ប៊ិន សំណាង ពិតជាពុំមែនឃាតករឡើយ ហើយសាក្សីជាច្រើនក៏បានអះអាងថា ពួកគេទាំងពីរពុំជាប់ពាក់ព័ន្ធក្នុងករណីឃាតកម្មលើលោក ជា វិជ្ជា ឡើយ ។ មិត្តស្រីរបស់ ប៊ិន សំណាង ជាជនជាតិយួនឈ្មោះ វៀង ធី ហុង និងម្តាយឈ្មោះ វៀង ធីងឿន បានអះអាងប្រាប់អ្នកស៊ើបអង្កេតសិទ្ធិមនុស្សថា "ពេលនោះ សំ ណាង កំពុងនៅក្រុងអ្នកលឿងជាមួយពួកគេក្នុងការប្រារព្ធពិធីបុណ្យចូល ឆ្នាំចិន-យួន ពួកយើងនៅជួបជុំគ្នាសប្បាយណាស់..." ។ ចំណែកឯសាក្សី របស់ សុខ សំអឿន ក៏បានអះអាងដែរថា គេមិនមែនជាឃាតករឡើយ ព្រោះនៅពេលនោះ សុខ សំអឿន កំពុងតែជាប់ដៃផឹកស៊ីនិងលេងបៀនៅឯទួលគោកឯណ្ណោះ ប៉ុន្តែក្នុងគ្រាដំណាលគ្នានោះ សាក្សីរបស់ សុខ សំអឿន មួយចំនួនបានបង្ហាញនូវអារម្មណ៍កង្វល់របស់ខ្លួនក្នុងការធ្វើជាអ្នកដឹងឮលើរូប សុខ សំអឿន ព្រោះនោះគ្មានអ្វីក្រៅពីរឿងសុវត្ថិភាពផ្ទាល់ខ្លួនឡើយ ។ រីឯមនុស្សម្នាក់ដែលជាសាក្សីសំខាន់ដែរបានប្រាប់ដល់ក្រុមអ្នកស៊ើបអង្កេតផ្នែកសិទ្ធិមនុស្សថា "បើគេអាចនាំខ្ញុំទៅកាន់ប្រទេសទីបីបានខ្ញុំនឹងនិយាយរឿងទាំងអស់..." ។ ក្រៅពីនោះ នៅមានសាក្សីសំខាន់ម្នាក់ គឺអ្នកស្រី វ៉ា សុធី ដែលជាម្ចាស់តូបកាសែត និងជាអ្នកដែលឃើញឃាតករដោយផ្ទាល់ភ្នែកនោះ បានអះអាងថា "ប៊ិន សំណាង និង សុខ សំអឿន ពិតជាពុំមែនមនុស្សដែលបាញ់លោក ជា វិ ជ្ជា នាពេលនោះឡើយ ។

ទោះជាមានការអះអាងយ៉ាងភ្លូកទឹកភ្លូកដីរបស់សាក្សី សុខ សំអឿន និង ប៊ិន សំណាង យ៉ាងណាក៏ដោយចុះ ក៏គ្មានអ្វីជាឧបសគ្គរបស់តុលាការឡើយ ហើយអ្នកទាំងពីរត្រូវតែដេកក្នុងពន្ធនាគារដោយអយុត្តិធម៌ ដើម្បីរង់ចាំការស៊ើបអង្កេត និងប្រមូលនូវភស្តុតាងបន្ថែម ។ លុះ១៨ខែ ក្រោយមកពោលគឺនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ ចៅក្រមបានរកឃើញថា អ្នកទាំងពីរពិតជាមានទោសហើយត្រូវបានជាប់ពន្ធនាគារក្នុងម្នាក់ៗចំនួន២០ឆ្នាំ ។ បន្ទាប់ពី៣ឆ្នាំនៅក្នុងពន្ធនាគារ គឺគេនៅចាំបានថាថ្ងៃទី៦ខែឧសភា ឆ្នាំ២០០៧ បណ្តឹងឧទ្ធរណ៍របស់អ្នកទាំងពីរត្រូវបានផ្ទុះឡើង ។ ពេលនោះគ្រួសាររបស់ សុខ សំអឿន និង ប៊ិន សំណាង មានសង្ឃឹមយ៉ាងមុតមាំគ្រប់ៗគ្នាថា ពួកគេទាំងពីរពិតនឹងត្រូវបានដោះលែង រីឯសាក្សីជាច្រើននៅតែអះអាងដដែលថា ពួកគេទាំងពីរពិតជាពុំមែនឃាតករឡើយ តែទោះជាយ៉ាងនេះក្តីចៅក្រមបានច្រានចោលនូវបណ្តឹងឧទ្ធរណ៍ ដោយមានហេតុផលថា សាក្សីនៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់រង់ចាំការស៊ើបអង្កេតជាបន្តទៀត ។ ដូច្នេះមានន័យថា អ្នកទាំងពីរត្រូវវាមានវាសនាអាក្រក់ត្រឡប់ទៅកាន់កន្លែងដើម គឺ "ជាប់គុក" បន្តទៀត ។

<u>ហេតុអ្វីបានជា ប៊ិន សំណាង និង សុខ សំអឿន ក្លាយជាចំណីចស៊ីបរបស់ប៉ូលីស?</u>

យោងតាមភាពយន្តឯកសារនោះបានបង្ហាញថា ប៊ិន សំណាង និង សុខ សំអឿន ពិតជាពុំបានពាក់ព័ន្ធលើឃាតកម្មលោក ជា វិជ្ជា ឡើយហើយ សូម្បីតែប្អូនបង្កើតរបស់លោក ជា វិជ្ជា គឺលោក ជា មុនី ដែលបច្ចុប្បន្នទទួលតំណែងស្នងពីបងប្រុសរបស់ខ្លួន ក៏បានអះអាងយ៉ាងច្បាស់ដែរថា អ្នកទាំងពីរពិតជាពុំមែនឃាតករឡើយ ប៉ុន្តែចំពោះអ្វីដែលឈានដល់ការចាប់ខ្លួនបុរសទាំងពីរនោះ គឺមានដំណើរហេតុដូចតទៅ:

សុខ សំអឿន ធ្លាប់បានស្គាល់បុរសម្នាក់ឈ្មោះ យិន ឡឿន អតីតជាចោរ ហើយឈ្មោះ យិន ឡឿន នេះ តែងតែយកគុកធ្វើជាផ្ទះរបស់ខ្លួន ប៉ុន្តែក្រោយមកប៉ូលីសបានបំពាក់បំប៉នស្មារតីដល់រូបគេ ដើម្បីធ្វើការឱ្យប៉ូលីស មានន័យថា ប៉ូលីសឱ្យចេញក្រៅគុក ដើម្បីស៊ើបមើលថា នរណាជាចោរខ្លះ ទើបរាយការណ៍ឱ្យប៉ូលីសចាត់ការ ។ ប៉ុន្តែ ដោយសារ សុខ សំអឿន ធ្លាប់ឈ្លោះគ្នាជាមួយ យិន ឡឿន នេះទើបធ្វើឱ្យ សុខ សំអឿន មានវាសនាអាក្រក់ធ្លាក់ខ្លួនជាឃាតករសប្បនិម្មិត ដោយការឆ្លើយដាក់គ្មានមូលដ្ឋានពីសំណាក់ យិន ឡឿន ដែលជាគូរបដិបរបស់ខ្លួន។

រីឯ ប៊ិន សំណាង មានប្រវត្តិជាអតីតអ្នកបំរើការងារក្នុងក្រុមហ៊ុនឯកជនលក់ថ្នាំពេទ្យមួយនៅភ្នំពេញឈ្មោះក្រុមហ៊ុន "សំណាង ហ្វារម៉ា" ។ ប៊ិន សំណាង បានលួចលុយក្រុមហ៊ុន (ស៊ីដាច់) ដែលជាហេតុធ្វើឱ្យម្តាយរបស់ខ្លួន គឺអ្នកស្រី ទួន គីមស្រី ខឹងដាច់ក្បាលដាច់កន្ទុយរហូតឈានដល់ "កាត់កាល" កូនចោលព្រោះមកពីខ្លាចខាងក្រុមហ៊ុនហ្វារម៉ារឹបអូសយកផ្ទះរបស់អ្នកស្រីជាថ្នូរនឹងលុយដែល ប៊ិន សំណាង បានស៊ីដាច់ ។ ពេលនោះអ្នកស្រីក៏បានយករូបថតកូនប្រុសរបស់ខ្លួនមួយសន្លឹក ដែលថតនៅកំពង់សោមឱ្យទៅប៉ូលីសមូលដ្ឋាន...។ ដោយសារតែ ប៊ិន សំណាង មានរូបថតនៅក្នុងដៃប៉ូលីសស្រាប់បែបនេះហើយ ទើបធ្វើឱ្យប៉ូលីសមានការងាយស្រួលក្នុងការគូសគំនូសព្រៀង ដែលចំលងចេញពីរូបថតហើយឈានដល់ការចាប់ខ្លួនតែម្តង។

រឿងរ៉ាវរបស់អ្នកទាំងពីរ ត្រូវបានក្លាយជាចំណុចក្តៅរបស់ក្រុមអ្នកកាសែត ជាពិសេស គឺអ្នកប្រម៉ាញ់ព័ត៌មានបរទេសតែម្តង ហើយភាពយន្តឯកសារ "ឃាតករសិប្បនិម្មិត" ក៏ត្រូវបានគេផលិតឡើងក្រៅពីនោះ អង្គការសង្គមស៊ីវិលនានា តែងតែទាមទារឱ្យមានការដោះលែងអ្នកទាំងពីរជាបន្ទាន់ក្រោមរូបភាពផ្សេងៗគ្នា ។ ដោយសារចរន្តឥតឈប់ឈររបស់ក្រុមផ្សេងៗនេះហើយ ទើបនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ អ្នកទាំងពីរត្រូវបានគេដោះលែងឱ្យនៅក្រៅឃុំ ដើម្បីរង់ចាំកាត់ទោស តែរហូតមកដល់ពេលនេះ អ្នកទាំងពីរពុំត្រូវបានគេកោះហៅ ឬចាប់ខ្លួនឱ្យវិលទៅកាន់ពន្ធនាគារវិញឡើយ ទាំងនេះមានន័យថា "អ្នកទាំងពីរពិតជាមានសេរីភាពរួចពីទុក្ខទោសមែន ឬទេ?"

ចុងក្រោយនៃភាពយន្តឯកសារ "នរណាសម្លាប់ ជា វិជ្ជា" ត្រូវបានរៀបរាប់ថា អ្នកស្រី ជា គីមនី ភរិយាលោក ជា វិជ្ជា និងកូនៗ បានទទួលនូវសិទ្ធិជ្រកកោនផ្នែកនយោបាយនៅប្រទេសហ្វាំងឡង់ រីឯអ្នកស្រី វ៉ា សុធី ជាសាក្សីដ៏សំខាន់បំផុតនោះ ក៏ត្រូវបានទទួលសិទ្ធិជ្រកកោនផ្នែកនយោបាយនៅសហរដ្ឋអាមេរិក បន្ទាប់ពីអ្នកស្រីត្រូវបានគេចខ្លួនទៅកាន់ប្រទេសថៃអស់មួយរយៈនោះ ។ ចំណែកស្នងការក្រុងជើងខ្លាំងឈ្មោះ ហេង ពៅ ដែលជាអ្នកចាត់ចែងលើសំណុំរឿង ប៊ិន សំណាង និង សុខ សំអឿន នោះត្រូវបានធ្លាក់ខ្លួនជាជនរងគ្រោះជម្លោះនយោបាយ ហើយត្រូវបានជាប់គុកចំនួន៩៧ឆ្នាំ ក្នុងបទមនុស្សឃាត ព្រមទាំងបទឧក្រិដ្ឋផ្សេងៗទៀត ដែលមិនទាក់ទងនឹងលោក ជា វិជ្ជា ។ រីឯមេប៉ូលីសចង្កូលមេឃ ឆេះមេឃចង្កូលផ្កាយឆេះ ផ្កាយឈ្មោះ ហុក ឡង់ឌី ត្រូវបានស្លាប់យ៉ាងតែហោង ដោយការធ្លាក់ឧទ្ធម្ភាចក្រ កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៨ កន្លងមកនេះ៕


**បណ្ណទិញបញ្ជាកាសែតខ្មែរប៉ុស្តិ៍**

ឈ្មោះ និងអាស័យដ្ឋានរបស់

ឈ្មោះ :......................................................................

អាស័យដ្ឋាន : ................................................................

**ខ្ញុំចង់បាន :**

☐ កាសែតខ្មែរប៉ុស្តិ៍ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ $70 អឺរ៉ូ សម្រាប់អឺរ៉ុប

☐ សៀវភៅរឿងឈ្មោះ ...............................តម្លៃ $..................

☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង តម្លៃមួយសិត $30

ខ្ញុំភ្ជាប់សែក ឬ មនីអឌ័រ មក U.A.M.G តម្លៃ $..................

ផ្ញើមក U.A.M.G 438 LINDLEY AVE. PHILADELPHIA, PA 19120

**Phone : 267-253-3947**

ភោជនីយដ្ឋានកូរ៉េ
សេអូរ៉េបូល
Seorabol Korean Restaurant

Add: 5734 Old 2nd street
Philadelphia PA 19120



# ភោជនីយដ្ឋានកូរ៉េដ៏ល្បីឈ្មោះនៅហ្វីឡាដែលហ្វៀ



- មានសាច់អាំង"បាបេគ្យូ"របៀបកូរ៉េ
- មានម្ហូបជប៉ុនគ្រប់យ៉ាង-ស៊ូស៊ី ។ល។
- មានភេសជ្ជៈ"ស្រាវ៉ាញកូរ៉េ"ផ្អែមហើយឆ្ងាញ់គ្រប់ប្រភេទ
- មានបន្ទប់"ភ្ញៀវកិត្តិយស VIP" បរិយាកាសយ៉ាងប្រសើរ សម្រាប់ភ្ញៀវពី១០ទៅ ៨០នាក់
- មានកន្លែងចតរថយន្តធំទូលាយ



**215-924-3355**

## SEO RA BOL
Sushi & sasimi
KOREAN • JAPANESE RESTAURANT
(Mon,- Satr: 11am to 11pm)(Sunsay: 11am to 10 pm) www.seorabolphilly.com

BBQ HOUSE
서라벌회관
(215) 924-3355



# អាហារដ្ឋាន "ប៊ូហ្វេ"

**Mandarin Buffet**
Parkway Plaza
1100 Revere Beach Parkway
Chelsea, MA 02150
617-889-0056
WWW.mandarinbuffetma.com
We have a full liquor license

**China Buffet**
Next to Target
203 Plain St.
Lowell, MA 01852
978-937-8868
WWW.chinabuffetma.com
Beer and Wine only

**China Buffet**
K-Mart Plaza180 Main
St.Saugus, MA 01906781-231-1588
Beer and Wine only



Buffet includes American & Chinese food bar, Japanese sushi bar, BBQ & grill, fruits,salad bar, ice cream, dessert cakes and much much more!



**ALL YOU CAN EAT BUFFET... !!!**


SATURDAY OCT 29
CLUB POLARIS
9pm - 2am
សុភាព
បញ្ញារី
SKY
Halloween PARTY
$15
FEATURING: PANHAREE THANG & GUEST SINGER: SKY
with KAVEI BAND & SECRET WEAPON BAND
at CLUB POLARIS 460 N 9TH STREET, PHILADELPHIA, PA 19123
WIN PRIZES FOR BEST HALLOWEEN COSTUMES! PARTY TILL 2AM!
Sponsored by KAVEI Xpress
Kavei
EAT IN - TAKE OUT
215.755.2151
AUTHENTIC CAMBODIAN CUISINE
2223-25 S 7TH STREET, PHILADELPHIA, PA 19148